# សម្ភាសជាមួយឈ្មោះ នួន ធិន ភេទ ប្រុស អាយុ៦៨ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈកងទ័ពក្នុងកងពល១៦៤ឈរជើងនៅកំពង់ផែស្ទឹងហាវ

## មានស្រុកកំនើតនៅភូមិដុកធ្លូក ឃុំដងទង់ ស្រុកដងទង់ ខេត្តកំពត

## សព្វថ្ងៃរស់នៅភូមិទួល ឃុំបារាំងធ្លាក់ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

## ថ្ងៃទី០៥ ខែមិនា ឆ្នាំ២០១៥

## សម្ភាសន៍ដោយៈឡុង ដានី និងសុខ វណ្ណៈ

០១:០០:១៦

## សរុបៈ៣៨

ដានី : អឺ ខ្ញុំចង់សួរនាំពីប្រវត្តិអ៊ំបន្តិច ។ មូលហេតុអ៊ីបានទៅដល់កោះពីមុន?

ធិន : កាលមុនខ្ញុំនៅធ្វើជាយោធា ។

ដានី : បាទ, ប៉ុន្តែអ៊ំដំបូង ខ្ញុំចង់ស្គាល់ពីឈ្មោះអ៊ំសិន តើឈ្មោះអ៊ំពេញឈ្មោះអីដែរ?

ធិន : ខ្ញុំឈ្មោះ នួន ធិន ។

ដានី : បាទ?

ធិន : នួន ធិន ។

ដានី : នួន ធិន ហ៎?

ធិន : បាទ ។

ដានី : អឺ ហឺរ, អ៊ំអាយុប៉ុន្មានហើយ?

ធិន : ៦៨ ។

ដានី : អ៎ អ៊ំអាយុនេះដែរ ច្រើនដែរហើយ!

ធិន : នឹងហើយ ។

ដានី : អ៊ំស្រុកកំណើតកើតជានៅឯណាដែរ?

ធិន : កំពត ។

ដានី : នៅកំពត?

ធិន : បាទ ។

ដានី : ភូមិអី ឃុំអីដែរ?

ធិន : នៅភូមិទឹកធ្លូក ឃុំទទង់ ស្រុកទូកមាស ឥឡូវ ។

ដានី : ភូមិដុកធ្លូក!

ធិន : ដុកធ្លូក ។

វណ្ណៈ : យុំ?

ធិន : ឥឡូវគេកាត់មកឃុំដង់ទង់ហើយ ។

វណ្ណៈ : ឃុំដងទង់ ស្រុកទូកមាស!

ធិន : ឃុំដងទង់ ស្រុកដងទង់ដែរហើយឥឡូវនឹង ។

វណ្ណៈ : ហ៎ ដូចអត់មានស្រុកដងទង់ទេ ឥឡូវនឹង?

ដានី : ស្រុកមាន មាន

ធិន : ស្រុកដងទង់ ។

ដានី : ចុះកាលពីមុន?

ធិន : ពីមុនស្រុកបន្ទាយមាស គេហៅថាឃុំ ឃុំ ឃុំទូក អឺរ ឃុំបន្ទាយមាស ។

ដានី : នៅកាលមុនអឺរ នៅក្នុងឃុំដុកធ្លក នឹង ឃុំ!

ធិន : ឃុំទទង់ ។

ដានី : ឃុំទទង់ ។

ធិន : ឃុំទទង់ ស្រុកទូកមាស ប៉ុន្តែឥឡូវនឹង គេដាក់ស្រុកដងទង់ ឃុំដងទង់វិញ ។ វានៅកណ្តាល ហើយ ។

ដានី : អឺរ ណាក់ សួរខ្ញុំកត់ ។

វណ្ណៈ : ចឹងអ៊ំ អ៊ឺ អឺ ហើយឥឡូវបច្ចុប្បន្ន អ៊ំនៅភូមិអី នៅក្នុងឃុំអី?

ធិន : ភូមិទួល ។

វណ្ណៈ : នេះភូមិទួល ណេស៎!

ធិន : ចា៎ ។

វណ្ណៈ : ឃុំ?

ធិន : ឃុំបារាំងធ្លាក់ ។

វណ្ណៈ : ស្រុក?

ធិន : ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។

វណ្ណៈ : ខេត្តបាត់ដំបង ។ ចា៎, ហើយ ឪពុករបស់អ៊ំឈ្មោះអីដែរ?

ធិន : នួន ធេង ។

វណ្ណៈ : បាទ, ចុះម្តាយ?

ធិន : អេប ហ៊ី ។

វណ្ណៈ : អេប?

ធិន : អេប ហ៊ុ ។

វណ្ណៈ : អេប ហ៊ុ ហ៎?

ធិន : ប៎ាទ ។

វណ្ណៈ : អ៊ំមានបងប្អូនប៉ុន្មាននាក់ដែរ?

ធិន : បងប្អូនខ្ញុំ បងប្អូន៥នាក់ ប៉ុន្តែស្លាប់អស់បីហើយ នៅសល់ ស្លាប់អស់ពីរ នៅសល់៣ ។

ដានី : ឪពុក ម្តាយអ៊ំស្លាប់អស់ហើយ?

ធិន : ស្លាប់អស់ហើយ ខ្ញុំអត់ទាន់ ។

វណ្ណៈ : បាទ ។ ហឺរ អឺរ ៥នាក់ នឹងស្រីប៉ុន្មាន ប្រុសប៉ុន្មានដែរក្នុងនឹង?

ធិន : ប៉ុន ទាលតែមានប្អូនប្រពន្ធចុង៨ទៀតឯណុះ ។

វណ្ណៈ : ប៎ា, ប៉ុនយើងនិយាយគិត មិនបាច់និយាយទេ ។

ធិន : ប៎ា

វណ្ណៈ : ៥នាក់ ។ បងប្អូនពូបង្កើត៥នាក់នឹងស្រីប៉ុន?

ធិន : ស្រី១ ។

វណ្ណៈ : ស្រីតែមួយទេ ណ្ហេស៎! ហើយពីនាក់ទៀតស្លាប់ដោយសារមូលហេតុអី?

ធិន : ដោយសារជំងឺ ។

វណ្ណៈ : ជំងឺទេ ណ្ហេស៎ ។ ចុះពូកាលពីនៅក្មេងៗ ពូបានរៀនសូត្រ? បានបួសរៀន អីទេ?

ធិន : បានតែបួស បានបួសខ្លះ ។

វណ្ណៈ : បួសនៅវត្តណា?

ធិន : វត្តធាយ ។

វណ្ណៈ : វត្តព្រះធាយ ហ្ហ៎?

ធិន : វត្តធាយ ។

វណ្ណៈ : វត្តធាយ ហ្ហ៎?

ធិន : បាទ ។

វណ្ណៈ : បួសបានប៉ុន្មានវស្សារដែរ?

ធិន : បួសបាន ហ្ហ៎ បែប ៧, ៨ នឹង បង ។

វណ្ណៈ : ហឺរ បានច្រើន ។

ធិន : ប៎ាទ ។

វណ្ណៈ : ដល់ឆ្នាំណាពូសឹកវិញ?

ធិន : ឆ្នាំ៧០ ។

វណ្ណៈ : ៧០? មូលហេតុអីបានពូសឹកវិញ?

ធិន : ធ្វើរដ្ឋប្រហារ ។

វណ្ណៈ : ដោយសារមានរដ្ឋប្រហារ ណ្ហេស៊់?

ធិន : កាលភ្លាមៗ ធ្វើរដ្ឋប្រហារគេនឹងឲ្យសឹកលោកអស់ ។

វណ្ណៈ : ចឹង ហ៊្អេ ។

ធិន : សឹកលោកអស់ យើងសឹក ។

វណ្ណៈ : ចឹងនៅក្នុងកន្លែង នៅក្នុងភូមិឃុំពូរស់នៅនឹង កន្លែងនឹងកន្លែងជាតំបន់រំដោះហើយចឹង ណ្ហេស៊់?

ធិន : អត់ទេ នៅនឹងប្រទង់ប្រទែងទាំងអស់នឹង ។

វណ្ណៈ : ប្រទង់ប្រទែងជាមួយលន់ នល ហ៊្ហេ់កាលហ្នឹង?

ធិន : អ៊

វណ្ណៈ : ដល់ពេលរដ្ឋប្រហារហើយរដ្ឋាភិបាលលន់ នល គ្រប់គ្រងៗ មិនចឹង? អរ, កាលនឹងពូពេលសឹកហើយនឹងពូអឺរ រៀបការហើយនៅ?

ធិន : នៅទេ ។

វណ្ណៈ : នៅទេ? មិនទាន់រៀបការទេ ។

ធិន : ហើយ ខ្ញុំនិយាយសឹក សឹកហើយខ្ញុំមកនៅក្នុងភូមិបានមួយឆ្នាំ ។

វណ្ណៈ : បានមួយឆ្នាំ?

ធិន : ប៉ា ។ នៅធ្វើ ។

វណ្ណៈ : ចឹងដល់ពេលឆ្នាំ៧១ បានពូចូលបំរើយោធា?

ធិន : កងទ័ព ។

វណ្ណៈ : កងទ័ព ណ្ហេស៊់ ។ ប៉ា, ពេលចូលដំបូងនឹង គេបង្ខំពូ ឬក៏ពូនឹកឃើញស្ម័គ្រចិត្តថាម្ដេច?

ធិន : អត់មានពីណាបង្ខំទេកាលនឹង ។

វណ្ណៈ : អត់មានទេ ។

ធិន : មានណាយើងបង្ខំទេ ។ កាលនឹងយើងវាថាយើងមករំដោះជាតិចេញពីណា អាមេរិកកាំង ហ្នឹង ។ អាមេរិកកាំងឈ្លានពាន ចឹងយើងនឹង គេធ្វើរដ្ឋប្រហារហើយ យើងនឹងប្រូង សម្ដេចវិញណា ។

វណ្ណៈ : ប៉ាទ ។

ធិន : មានណាបន្តិ ។

វណ្ណៈ : ចឹងដូចគិតថាយើងចូលនឹងចូលដើម្បី ដូចថាយើងជួយសម្ដេចវិញ?

ធិន : ប៊ាទ ។

វណ្ណៈ : នឹកឃើញថាចឹង ណ្ហេស៊?

ធិន : ប៊ាទ ។

វណ្ណៈ : ប៊ា ។ ហើរនៅក្នុងភូមិរបស់ពូនឹងចូលនឹងគ្នាច្រើនទេ យុវជនកាលនឹង?

ធិន : ច្រើនណាស់អស់ពីភូមិ ។

វណ្ណៈ : អស់ច្រើន ម៉ង!

ធិន : អស់ ។

វណ្ណៈ : ចូលទៅ ។

ធិន : ធ្វើកងទ័ពនឹង ។

វណ្ណៈ : នឹងហើយ ។

ធិន : យើងមកថារំដោះឲ្យសម្ដេចឪមកវិញនុះ ។

វណ្ណៈ : ចូលដំបូងពេល ចូលដំបូងពូទៅ ទៅម្តុំណាដែល អឺរ ដំបូងនៅក្នុងភូមិដដែល ស្រុក ឬក៏ទៅខេត្តគេផ្សេង?

ធិន : អត់ទេ, នៅតំបន់កំពតដដែល ។

វណ្ណៈ : បាទ ។

ធិន : មុនដំបូងខ្ញុំចូលមកឃុំបានមួយអាទិត្យទេ យើងកុំបាច់និយាយទេ ។

វណ្ណៈ : ប៊ាទ! មកឃុំមួយអាទិត្យ ។

ធិន : បានមកឡើងទៅភាគម៉ង ឡើងទៅតំបន់ ។

វណ្ណៈ : ប៊ា, តំបន់ ។

ធិន : តំបន់កំពតនោះ ។

វណ្ណៈ : តំបន់ប៉ុន្មានកាលនឹង?

ធិន : នៅកងពល តំបន់ ។ អឺ វរសេនាធំប៉ុន្មានទេភ្លេចហើយ កងពល ១០ប៉ុន្មានហើយទេ ។

វណ្ណៈ : ពីណាប្រធានកងពលកាលនឹង?

ធិន : កងពល អ៊ើ ភ្លេចដែរហើយនឹង ភ្លេចអស់ហើយ យូរពេកហើយ ។

វណ្ណៈ : ចុះអុំដូចថានៅ នៅឈរជើងនៅខាងតំបន់ នៅខេត្តកំពតនឹងរយៈពេលប៉ុន្មាន គេបញ្ជូនទៅណាណីទៀត ហើយបានឡើងមកភ្នំពេញទេ ហើយបានឡើងមកវៃមកអីនៅភ្នំពេទេ?

ធិន ៖ ឈប់, ខ្ញុំនិយាយមុននឹងហា ។

វណ្ណៈ ៖ ប៉ាទ ។

ធិន ៖ ឡើងមកនៅកង៦១ ។ ៦១ចឹងហើយ ។ កងទិត នោះគេមកនៅ មកវ៉ៃនៅវ៉ៃក្រាំងស្វែង នៅខាងត្បូងភ្នំពេញនោះ

ដានី ៖ វត្តស្វែងហ៎?

ធិន ៖ បាទ! វត្តស្វែងនេះ ចេញពីហ្នឹងទៅ គេបញ្ជូនទៅកំពតវិញ ។ ទៅវ៉ៃកំពតវិញស្លាប់អស់ច្រើន ។

ដានី ៖ អានឹង កាលនឹងអឺរ អ៊ំនៅក្នុងកងអី? កង៦១ ។

ធិន ៖ ប៉ាទ ។

ដានី ៖ កង៦១នឹងជាកងអីគេ ជាកងវរៈ ឬក៏កងពល?

ធិន ៖ កងវរៈ ។

ដានី ៖ វរៈ៦១?

ធិន ៖ បាទ!

ដានី៖ កាលនឹងជាវរសេនាតូចនៅឡើយ ឬក៏?

ធិន៖ វរសេនាតូច ។

ដានី ៖ វរសេនាតូច៦១ ។

វណ្ណៈ ៖ កងពល អ៊ំអត់មានចាំលេខកងពលនឹង?

ធិន ៖ កងពលលេខប៉ុន្មានទេ!

ដានី ៖ កាលនឹងអ៊ំមានកងពលនៅ?

ធិន ៖ មានហើយគ្រូ ព្រោះប៉ុនភ្លេច ហើយកងពល ។

ដានី ៖ កងពលប៉ុន្មាន? មាន កាលនឹងវាមានកងពលលេខ០១, ០២, ០៣ ។

ធិន ៖ ៥១, ៥៣, ៥១, ៥៣, ៦៦, ៦១ ចឹងហ៊ីរតូ ។ កងពល៦១ ចឹងហ៊ីរ!

វណ្ណៈ ៖ អានឹង លេខវរៈទេហ៊ីរ?

ធិន ៖ វរសេនាធំ ។

វណ្ណៈ ៖ វរសេនាធំ ប៉ុន្តែចង់និយាយពីកងពលទាំងមូលតែម្តង ។

ធិន ៖ កងពល នៅកងពលប៉ុន្មានហើយទេតូភ្លេចហើយ ។

វណ្ណៈ ៖ ពីណាដឹកនាំកាលនឹង? ជិនាន់នឹង? ជិនាន់៧២, ៧៣ អីនឹង? ប្រធានកងពល ប្រធានធំហ្នឹង?

ធិន :	ឈ្មោះអីហើយទេ ចុង១មាត់ហើយ ។ តើត ។

វណ្ណៈ :	ឈ្មោះតាកើត ។

ធិន :	កើត ។

វណ្ណៈ :	តាកើតនឹង ក្រោយមកគាត់ស្លាប់ហើយ?

ធិន :	បាទ, ស្លាប់ហើយ ។

វណ្ណៈ :	ស្លាប់ជំនាន់ណាដែល?

ធិន :	ស្លាប់ ស្លាប់បែកគ្នាពីព្រោះពេលដល់អាពេលបែក អឺរអាររំដោះហើយ បែកគ្នាម៉ង់ ខ្ញុំគេបញ្ជូនមកកំពត ។ ណាស់! គេបញ្ជូនមកកំពង់សោមមក ។

ដានី :	អរ អញ្ចឹងលោកពូពេលដែលលោកពូ អឹអឺរ វិនៅកំពតអីហើយ ។

ធិន :	រំដោះហើយអីហើយ ចឹង រំដោះគេបំបែកភ្នំពេញហើយដល់នឹងគេ វិលែងមកនៅ ដកខ្ញុំមកវិរសេនាតូចនឹង មកកំពង់សោម ។

វណ្ណៈ :	បាទ!

ធិន :	មកកំពង់សោម ។

វណ្ណៈ :	ចុះអ៊ំអត់មានបានឡើងមកវិចូលមកដល់ភ្នំពេញទេ អត់បានទេ?

ធិន :	អត់បានទេ ។

វណ្ណៈ :	បកទៅកំពតវិញ ។ ហើយអ៊ំថាមនុស្ស មនុស្សស្លាប់ច្រើន ស្លាប់ខាងណាពេលវិនឹង? ស្លាប់ខាងខ្មែរក្រហម ឬក៏ខាងលន់ នល?

ធិន :	ខាងខ្មែរក្រហម ។ អានឹង កាលនឹងមិនទាន់ថាចែកខ្មែរក្រហមខ្មែរអីផង ។ កាលនឹងនៅខ្មែររំដោះទាំងអស់មិនទានថាខ្មែរក្រហមទេណា ពូណា ។ នៅកាន់កាប់ ។ វាមិនទាន់ប្រកាសថាខ្មែរក្រហមទេ នៅក្នុងស្រុកយើង កងរំដោះជាតិទាំងអស់គ្នា ។

វណ្ណៈ :	អត់ទាន់ហៅថាខ្មែរក្រហមទេ?

ធិន :	អត់ទេ ។ ដល់អាពេលរំដោះហើយនេះបានចេញមកខ្មែរក្រហមនេះនែក ។ ខ្មែរក្រហមអានឹងរំដោះហើយប្រទេសហើយ គេរៀបចំទៅជាបក ។ស្ស

ដានី :	ខ្មែរក្រហម ។

ធិន :	ចេញ ប៉ុល ពត មក ។

ដានី :	ឆ្នាំ៧៥?

ធិន :	បាទ ។

ដានី :	អញ្ចឹងដល់ពេលឆ្នាំ៧៥ គេដកអឺរ ក្រុមអ៊ំមួយវិរសេនាតូចនឹងអោយទៅកំពង់សោម?

ធិន ៖ បាទ ៗ រំដោះហើយចេញ រំដោះប្រទេសហើយនឹង ឲ្យមករៀបមក មកនៅខ្មែរ នៅកំពង់សោម ៗ

ដានី ៖ ហឺរ, គេប្រាប់ថាម៉េចកាលនឹង?

ធិន ៖ ប្រាប់ថាមកទៅកំពង់សោម ទៅរៀបចំនៅកំពង់សោម ៗ

វណ្ណៈ ៖ បាទ ៗ

ធិន ៖ មក គេរំលាយកងទ័ពរំលាយវរៈសេនាតូចនឹងឲ្យទៅនៅជាមួយចំរុះគេទាំងអស់នឹងណាស់ ៗ

ដានី ៖ អរ...., បាទ ៗ

ធិន ៖ ទៅអានោះ៥០ អានោះ២០នាក់ចឹងទៅគេដកយកទៅដាក់ចំរុះគ្នាគេអស់ចឹងទៅណាស់ ៗ

ដានីៈ ៖ អឺរ.....,ទៅដាក់កំពង់សោម ទៅជាកងពលអីវិញទៅ?

ធិន ៖ ៦៤ ៗ

ដានី ៖ កងពល១៦៤?

ធិន ៖ បាទ, តាមុត ៗ

ដានី ៖ តាមុត អឺ!

ធិន ៖ ប៉ា៎ ៗ

ដានី ៖ ពេលចឹងទៅដល់កំពង់សោមគេហៅកងពល១៦៤ដែរ?

ធិន ៖ ប៉ា៎ ៗ

ដានី ៖ កាលកំពត អត់ទាន់១៦៤ទេ?

ធិន ៖ បាទ, នៅទេ ៗ

ដានី ៖ កងពលរបស់តាមុត?

ធិន ៖ អើ, កងពលតាមុត ៗ

វណ្ណៈ ៖ មានតាមុត មានពីណាទៀតនៅ អឺរ ដែលជាអនុកងពល អីនឹង?

ធិន ៖ តាសារឿន, តាង៉ែត បីនាក់ហ្នឹង តាង៉ែតនេះអានឹងគេចាប់ហើយ ៗ

វណ្ណៈ ៖ គេចាប់ហើយ!

ធិន ៖ បាទ ៗ ហឺរអឺ, តាសារឿននេះ អត់ចាប់ទេ មកចាប់នៅនេះ ៗ

ដានី ៖ តាមុត?

ធិន ៖ តាមុត នៅកោះកុង ៗ នៅកោះកុងរាល់ថ្ងៃ ៗ

ដានី ៖ ឥឡូវគាត់នៅកោះកុង?

ធិន ៖ បាទ ៗ

ដានីៈ : កោះកុង កន្លែងណាទៅ?

ធិន : កោះកុង នៅម្តុំ ម្តុំ មិនដឹងម្តុំណា ៗ ម្តុំចើងរនោង ហើយនៅម្តុំភូមិ ភូមិអីគេ ភូមិ...

ដានី : សំលូត, វាលវែង, ថ្មរដាអីនឹង?

ធិន : បាទ ៗ ម្តុំនឹង ប៉ុន្តែខ្ញុំមិនដឹងគេហៅភូមិអី ៗ

ដានី : អានឹងគេហៅ គេហៅកោះកុង កោះកុងចឹងទៅ!

ធិន : បាំ, មួយដួរនឹងភូមិវាលតី ភូមិអីនឹងគេហៅកោះកុងហើយអានឹងណា ៗ

ដានី : បាំ ៗ ចុះអ៊ីចឹង ពេលដែលអ៊ីរ ក្រុមវរសេនាតូចមក មកកំពង់សោម បញ្ចូលជាមួយកងពល៦៨?

ធិន : បាទ ៗ

ដានី : កាលនឹងកងពល១៦៨នឹងមានប៉ុន្មានវរសេនាធំទៅ?

ធិន : បី, បី វរសេនាធំ ៗ

ដានី : បី វរសេនាធំ?

ធិន : បាទ ៗ

ដានី : វរសេនាធំមានលេខទេកាលហ្នឹង?

ធិន : បាទ, មាន ៗ

ដានី : លេខប៉ុន្មានទៅ?

ធិន : ៦១ ខ្ញុំ ៗ

ដានី : លេខ ៦១ អ៊ុំ ៗ

ធិន : បាទ ៗ

ដានី : ហើយចុះ៦២?

ធិន : ៦៣ ៗ

ដានី : ៦៣ ៗ ហឺរ, ៦១, ៦២, ៦៣ ៗ

ធិន : បាទ ៗ

ដានី : ហើយអ៊ុំនៅក្នុងវរសេនាធំ៦១?

ធិន : ៦១ ៗ

ដានី : ៦១, តីណាគេធ្វើប្រធាន?

ធិន : ភាព ៗ

ដានី : ឈ្មោះភាព?

ធិន :	បាទ ។

ដានី :	គាត់នៅរស់ ឬក៏ស្លាប់បាត់ហើយ?

ធិន :	ស្លាប់ហើយ ។

ដានី :	ស្លាប់ហើយ ។ អនុ ភាពមានពីណាទៀតដែរ ឬអត់?

ធិន :	មាន ប៉ុនភ្លេចហើយពូ មិនដឹង ភាព នឹង, តាយ៉ាន់ នេះ ។

ដានី :	តាយ៉ាន់ ។ គាត់នៅ ឬទេ តាយ៉ាន់?

ធិន :	មិនដឹងទៅណាអស់ហើយទេ បែកគ្នាអស់ហើយ ។

ដានី :	វរៈសេនាធំ៦១ នឹងឈរជើងនៅណាខ្លះទៅ?

ធិន :	៦១នេះ ៦១នេះ ខ្ញុំវាមានបីវរសេនាតូច ។ ៤វរសេនាតូចទៀតឯនោះ ក្លួយណាស់!

ដានី :	បាទ, បួនវរសេនាតូចទៀត ។

ធិន :	បាទ ។ ខ្ញុំនៅ៦១ ដែលនៅកាំភ្លើងធំ ។ ៦៤នេះកាំភ្លើងធំម៉ង ។ ខ្ញុំនៅ៦៤ ។

ដានី :	ចាំមើលវរសេនាធំ៦១ ហើយវរសេនាតូចលេខប៉ុន្មាន?

ធិន :	វរៈលេខ លេខ៦៤ ។

ដានី :	៦៤?

ធិន :	បា, នៅកាំភ្លើងធំ ។ កងកាំភ្លើងធំ ។

ដានី :	កងកាំភ្លើងធំ ។

ធិន :	នឹងហើយ ។

ដានី :	កាំភ្លើងធំនឹងយើងឈរជើងនៅណា?

ធិន :	នៅ, ទៅនៅឯកំពង់, កោះរ៉ុង អឺរ កោះរ៉ុងក្នុងក៏នៅ មកនៅស្ទឹងហាវជាប់ម៉ង ។ នៅស្ទឹងហាវនេះជាប់ហើយអានឹង ។

ដានី :	បា ។ អញ្ចឹងនៅ កោះរ៉ុងក្នុង ។

ធិន :	ហើយទៅនៅស្ទឹងហាវ ។

ដានី :	ស្ទឹងហាវ ។

ធិន :	នឹងដល់ស្ទឹងហាវនឹង វាដកច្រើនកន្លែងនៅ ។

ដានី :	ចុះ អ៊ំ ខ្ញុំសុំសួរតិចទៀត ចាំមើលអើ វរសេនាធំ៦១នឹង វាមានវរសេនាតូច៦៤, វរសេនាតូច ៦០ប៉ុន្មានទៀត?

ធិន :	៦៤, ៦៣, ប៉ុន្មានទេ វរសេនាតូច ប៉ុន្មានខ្លះទេគឺនៅ ។ មើលនែក ៦១នឹង វាមាននៅ កោះរ៉ុងផង នៅរៀមផង ។

ដានី :	បាទ៎! វរសេនាធំ ៦១នឹងនៅកោះរ៉ុងផង ។ កោះរ៉ុង មានរ៉ុងក្រៅ នឹង រ៉ុងក្នុង?

ធិន :	រ៉ុងក្នុង នឹង រ៉ុងក្រៅ ។

ដានី :	ក្នុង, ក្រៅ ។ ហើយនៅណាទៀត? វរសេនាធំ៦១ មានទាំងកោះរ៉ុងផង ហើយរៀម ។

ធិន :	នៅរៀម ។

ដានី :	នៅរៀម ។ នៅណាទៀតទៅអ៊ំ?

ធិន :	នៅរៀម នៅត្រពាំងពោធិ៍ នៅ ចែរន្ទេនេះ ភូមិចៃន្ទេ ។ ចៃន្ទេនេះនៅហួសពីកងកេង បន្តិចនៅព្រៃនប់នឹង ។

ដានី :	ចៃន្ទេ, ព្រៃនប់?

ធិន :	អានឹងកងវរសេនាតូចគឺនៅបំបែកវាមិនដឹងនៅឯណាខ្លះទេ ខ្ញុំដឹងតែកងខ្ញុំ កងកាំភ្លើងធំ មានការអីគេហៅទៅតែម្ដង, អានឹងហា! ចាំ វាពិបាកអាគេកងគេ គេបែកទៅមិនដឹង គេទៅនៅណាខ្លះ ។ អាវរសេនាធំ បី, បីវរសេនាធំកងពលនឹង មិនដឹងគេនៅឯណាខ្លះ?

ដានី :	បាទ៎ ។ ប៉ុន្តែវរសេនាធំ៦១នឹង ឈរបើតាមកោះវិញតែកោះរ៉ុងមួយទេ?

ធិន :	បាទ៎, រ៉ុងទៅ ហើយនឹង ។

ដានី :	រ៉ុងក្នុង?

ធិន :	រ៉ុងក្នុង ទៅនៅកោះតាង, កោះពូឡូវៃ ។

ដានី :	អញ្ចឹងនៅកងវរសេនាធំ៦១នឹងមានដែរ?

ធិន :	បាទ! វាមានបីកងវរសេនាតូច បីកងវរសេនាធំ ។ តែមិនដឹងគេបែកអានឹងគឺទៅនៅកោះណាខ្លះ ។ អាបីវរសេនាធំនឹងគេទៅកងណាទេ ។ ទៅនៅកោះពូឡូវៃក៏មិនដឹង ទៅនៅកោះតាងក៏មិនដឹងខ្ញុំអត់ដឹងទេណាស់! ខ្ញុំដឹងតែខ្លួនខ្ញុំតែម្ដង ខ្ញុំមួយកងវរសេនាតូចនឹង ទៅណាទៅទាំងអស់គ្នាតែម្ដង ។ អានេះគេបែកគ្នាមួយវរសេនាតូចៗនឹងមិនដឹងគេបែក វរសេនាធំគេនៅកោះណាៗ នឹងណា! វាពិបាកអញ្ចឹង ។ ប៉ុនអានេះដឹងតែវរសេនា កងពលនេះ ៦២នេះនៅពីវាលរេញ ទៅនៅកំពតត្រឹមកំពត មួយដួរកំពតហ្នឹង នែក ។

ដានី :	វរសេនាធំ៦២?

ធិន :	បាទ ។

ដានី :	៦២ ពីវាលរេញ វាលរេញទៅកំពត?

ធិន :	បាទ៎ ។ ហើយអានេះ ៦៣នេះនៅកោះថ្មី កោះអី ឯណោះ ។ ដឹងតែនៅម្ដុំកោះថ្មីអីនឹង ។

ដានី ៖ ៦៣ ខាងកោះ ។

ធិន ៖ កោះថ្មីជាប់នៅទឹងកំពត នៅខាងនេះកំពតទឹងមួយជួរ ។

ដានី ៖ បាទ, ប៉ុន បើនៅតាមកោះ កោះតាង កោះពូលូវៃ កោះអី ។

ធិន ៖ អានេះ៦១ នេះ ។

ដានី ៖ ៦១ នេះទេ ។

ធិន ៖ ខុសគ្នា ។

ដានី ៖ បាទ ។ អញ្ចឹង នៅពេលដែលអ៊ីរ អ៊ីដល់កំពង់សោមពេលដែលគេបញ្ជូលទៅ អ៊ីត្រូវបានគេបញ្ជូលនៅ វរសេនាធំ៦១ ។

ធិន ៖ បា៎ទ ។

ដានី ៖ វរសេនាតូច កាំភ្លើងធំ ចឹងហីរ?

ធិន ៖ បា៎ ។

ដានី ៖ វរសេនាធំកាំភ្លើងធំ៦១ ។

ធិន ៖ ៦១ ។

ដានី ៖ ដល់ពេលដំបូង អ៊ីនៅណាទៅ?

ធិន ៖ ដំបូង ហេរ?

ដានី ៖ បាទ, ដំបូងចូលទៅដល់កំពង់សោមដំបូង?

ធិន ៖ នៅ ភូមិថ្មី អានៅភូមិ ពីអូរគ្រេសបន្តិចមក ។

ដានី ៖ ហួសពីអូរគ្រេស ឆ្នេរអូរគ្រេសហ្នឹង ។

ធិន ៖ មកពីចំការដូងបេងហេង មកចូលមកបេះមក ។

ដានី ៖ បា៎ទ ។

ធិន ៖ ដឹងអូរគ្រេសទេ?

ដានី ៖ បា៎ទ! ស្គាល់តា៎ ឆ្នេរអូរគ្រេសឥឡូវ ។

ធិន ៖ មកបេះ មកមាន គេមានធ្វើផ្ទះ ផ្ទះយោធាអើយផ្ទះគ្រួសារយោធា ចេញពីអាចំការកៅស៊ូមក ផ្លូវចូលចុះទៅអញ្ចេះ មានទៅបេះមើលទៅឃើញផ្ទះ ផ្ទះគេរៀបចំឲ្យយោធានៅទេ ប៉ុន្តែមិនដឹងគេរុះ ខ្ញុំមកតាំងពី៧៩ មកនេះមក ។

ដានី ៖ បា៎ទ ។ ទៅដល់ដំបូងគេឲ្យធ្វើអីខ្លះទៅ?

ធិន ៖ នៅហាត់បច្ចេកទេស ។

ដានី ៖ ហាត់បច្ចេកទេស?

ធិន ៖ ហាត់បច្ចេកទេសទៅរៀនបច្ចេកទេស ។

ដានី ៖ បច្ចេកទេសនឹង អីគេអានឹង?

ធិន ៖ រឿងបាញ់កាំភ្លើងធំ ។

ដានី ៖ អ៊ំចេះបាញ់ឬទេ?

ធិន ៖ ចេះខ្លះ ។

ដានី ៖ ចេះខ្លះដែរ!

ធិន ៖ បាទ ។

ដានី ៖ អ៊ំកាន់ខាងអី ធ្លាប់អីរ?

ធិន ៖ ១២០ ។

ដានី ៖ កាន់អា ១២០ ។

ធិន ៖ បាទ ។

ដានី ៖ ធ្លាប់បាញ់ឬទេ?

ធិន ៖ ចុះបើយើងធ្វើទ័ពហើយមិនធ្លាប់ម៉េចន៎! ទាល់តែហ៊ាន ។

វណ្ណៈ ៖ ចុះកាលនឹងមានបាញ់ជាមួយយួន ជាមួយអីដែរ? កាលនឹង!

ធិន ៖ អត់បានបាញ់ទេ ។ បានបាញ់តែកាលយើងកំពុងនូវធ្វើសង្គ្រាមបន្ទាន់នឹង កាលនឹងបាញ់តិចៗទៅណា ។

វណ្ណៈ ៖ តែនៅលើកោះ ពេលនៅលើកោះ?

ធិន ៖ អត់ទេ, នៅលើកោះយើងអត់បានបាញ់ទេ ។

ដានី ៖ កាលអ៊ំនៅកំពត នៅអីអ៊ំធ្លាប់បានបាញ់អាកាំភ្លើងធំនឹងដែរ? ចឹងបានគេឲ្យអ៊ំនៅខាងកាំភ្លើងធំនឹង?

ធិន ៖ កាលនៅកំពត ខ្ញុំនៅចាំ៦១នេះ ខ្ញុំនៅកាន់៨០ ។

ដានី ៖ កាន់អា៨០!

ធិន ៖ បាទ ។ ៨០ នៅប្រចាំ កងហា ៥៧នេះ ។

ដានី ៖ បាទ! អ៊ំពេលដែល អញ្ចឹងពេលដែលទៅដល់កំពង់សោមដំបូងអ៊ំនៅកន្លែងភូមិថ្មីទេ កន្លែងជិតអូរត្រេស?

ធិន ៖ អូរទ្រេសនឹង ។

ដានី ៖ ជិតអូរទ្រេស?

ធិន ៖ នៅកន្លែងចំការដូងចេងហេងហ្នឹង ។

ដានី ៖ នៅហាត់បច្ចេកទេសនៅនឹង ។ ហើយហាត់បច្ចេកទេសនឹងហាត់យូរ ឬទេ?

ធិន ៖ ហាត់យូរក្រែលដែរ ១ខែជាង ។

ដានី ៖ បាទ ។ បានមួយខែជាងឯនោះ ។

ធិន ៖ ហើយបានទៅកោះ ចេញទៅនៅកោះ ។

ដានី ៖ ហាត់បានមួយខែជាងបានចេញទៅនៅកោះ?

ធិន ៖ ទៅ ។

ដានី ៖ ទៅកោះណា?

ធិន ៖ នៅកោះព្រីង ។

ដានី ៖ ដំបូងចេញពីហាត់នឹងទៅណា? ទៅកោះព្រីង!

ធិន ៖ បាទ! ទៅនៅកោះព្រីង អស់រយះ (គាត់មកសំភាសន៍ពីដើមគាត់សួរ) នៅកោះណា?

ដានី ៖ បាទ! អ៊ំនៅកោះព្រីង ដំបូងហាត់បានមួយខែ ពីកន្លែងភូមិថ្មី ពីជិតអូរព្រេសនឹងហើយគេបញ្ជូនទៅនៅកោះព្រីង?

ធិន ៖ បាទ ។

ដានី ៖ កោះព្រីងនឹងចម្ងាយប៉ុន្មានពី?

ធិន ៖ អ៊ូយ, ខ្ញុំអត់ដឹងទេឆ្ងាយមើលឃើញជាប់ដើងមេឃដូចដែរគ្នា ។

ដានី ៖ អូ...

ធិន ៖ ជិតកោះតាង, កោះពូលូវៃដូចតែគ្នា ។ លិច កើតកោះតាងហើយកោះព្រីង វានៅចេះដូចគ្នាឆ្ងាយ ។

ដានី ៖ កោះនឹងឆ្ងាយ, នៅចន្លោះ ពីព្រោះកោះតាង កោះតាងហើយកោះពូលូវៃនឹង, ពូលូវៃនៅឆ្ងាយជាងគេ ។

ធិន ៖ បាទ ។

ដានី ៖ កោះពូលូវៃមកកោះព្រីង កោះព្រីងមកកោះតាង?

ធិន ៖ កោះពូលូវៃចេញមកចេះមកកោះតាង ចូលមកក្នុងនេះកោះតាង ។ ចេញពីកោះតាងមកទៅលិច ទៅលិចចេះកោះព្រីង ។ ចេញពីកោះព្រីងទៅ ទៅកោះស្តេច ។ មានកោះស្តេចមួយនៅខាងលិច នៅជាប់នឹងដូវអន្តរជាតិដូចគ្នា ។

ដានី ៖ អីចឹងអ៊ំអាចជម្រាបខ្ញុំទាក់ទងពីបទពិសោធន៍ដំបូង ថាអ៊ំអត់ដែលធ្លាប់នៅកោះសោះ ទាល់តែគេបញ្ជូនទៅយ៉ាងម៉េចដែរដំបូង? ដំបូងគេពេលទៅកោះព្រីងតែម្តង ។

ធិន ៖ វាកំសត់ដូចតែគ្នាពូ កុំនិយាយអារឿងយើងកំសត់ទៅ យើងមិនដឹងទៅនិយាយយ៉ាងម៉េច បើយើងថាតាមបក្ស បំរើបក្ស បំរើប្រជាជន ការពារទឹកដី អានឹងយើងនិយាយតែប៉ុននឹង ។

ដានី ៖ អើ, ទៅកោះព្រីងនឹង អី ម៉ា វរៈកាំភ្លើងធំពូទៅតែម្ដង?

ធិន ៖ បាទ, មួយវរៈនឹង ។

ដានី ៖ ហឹ ។ ពីណាគេប្រធានវរៈកាលនឹង?

ធិន ៖ តាជុន ។

ដានី ៖ តាជុន ។ តាជុននឹងគាត់ប្រធានវរៈរបស់ អឺ អឺ?

ធិន ៖ បាទ ។

ដានី ៖ ចុះអនុ?

ធិន ៖ អនុ ស្អីហើយទេ! អនុ មិនដឹងពីណាគេហើយ ។

ដានី ៖ បាទ បាទ ។

ធិន ៖ ភ្លេចហើយ ។

ដានី ៖ បាទ បាទ ។ ចុះអឺ ក្នុង ម៉ា កោះព្រីងនឹងធំឬទេ? ទំហំប៉ុណ្ណាទៅអ៊ំ?

ធិន ៖ ដូចធំដែរ ។ ប្រហែល៥០០ម៉ែត្រ ។

ដានី ៖ បណ្ដោយ ហេរ?

ធិន ៖ បាទ ។

ដានី ៖ ហើយទទឹង?

ធិន ៖ ទទឹងប្រហែល៤នឹង ។ វាវាងចេះបើយើងដើរ ។

ដានី ៖ វាវាងបួនជ្រុងដែរ ។

ធិន ៖ បាទ ។

ដានី ៖ ហឺ, ដល់ពេលយើងទៅមួយវរៈអញ្ចឹងគ្នារាប់រយនាក់ ទៅនៅអត់ចង្អៀតទេ?

ធិន ៖ ទេ, តាមមុខព្រួញទៅ, តាមបែកទិសគ្នា ។ ដូចថាមួយកងហានៅខាងជើងចឹងទៅ មួយកងហានៅខាងត្បូង មកវាជុំគ្នាអញ្ចឹងមកដើរ ។

ដានី ៖ ហឺ មក មក ម្ហូប ស្បៀងអាហារអី ពីកំពង់សោមទៅ ឬក៏យើងធ្វើនៅនឹងខ្លួនឯង?

ធិន ៖ យកពីកំពង់សោមទៅ ។

ដានី ៖ កំពង់សោមទៅ ។

ធិន : អានឹងយើងគេថាបក្សដឹកទៅ យើងនិយាយបក្សទៅណា និយាយថាបក្សឧបត្ថម្ភឲ្យទៅម្តង អ្នកនៅកោះអត់ខ្វះខាតទេ ។ មួយថ្ងៃបីពេល ។ មួយថ្ងៃ អង្ករគេឲ្យពាក់កំបុង ហើយយើងហូបអស់អត់មួយនាក់ឯង! ហូបអត់អស់ទេ ប៉ុន្តែដល់ពេលនឹង អត់បានមករៀនសូត្រអីទេ និយាយថា ដល់នឹងគេសុំដកពីយោធាមកមួយរបប គេសុំមួយកំប៉ុងវិញ ។ មួយនាក់ណា! គេសុំយកមកឲ្យឧបត្ថម្ភឲ្យប្រជាជនខាងក្រោយខ្វះខាត ។ អានឹងបក្សលើកចឹងណា ខ្ញុំក៏លើកទៅតាមនឹងដែរ សុំថាឲ្យ អញ្ចឹងក៏ឯកភាពទាំងអស់គ្នាក៏ឲ្យអង្ករ ។ នឹងដកចុះមិនបញ្ហាអីទេ យើងនៅនោះ យើងហូបគ្រប់គ្រាន់ហើយយើងអីទៀត ។ មិនមានអីទេ យើងមានកូនប្រព័ន្ធមកពីណា បើមានតែយោធានឹង ។

ដានី : បាទ ។ អញ្ចឹង អ៊ំ ពេលដែលអ៊ំមកនៅកំពត ពេលបែកឆ្នាំ៧៥ យើងរំដោះហើយភ្លាមគេបញ្ជូនអ៊ំទៅ មកកំពង់សោមភ្លាម?

ធិន : ទៅនៅបន្ទាយមាសបានប៉ុន្មាន ពីរ បីអាទិត្យដែរ ។ ទៅធ្វើស្រែនឹងគេឲ្យអូសន័ង្គល ។ យើងនិយាយថាអូសអញ្ចឹងទៅណា ។

ដានី : បន្ទាប់ពីនៅធ្វើស្រែ នៅបន្ទាយមាសនឹងបាន២-៣អាទិត្យបានគេបញ្ជូនមកកំពង់សោម?

ធិន : បាទ ។

ដានី : ពេលបញ្ជូនមកកំពង់សោម..., ពេល ពេល បញ្ជូនមកកំពង់សោមមានព្រឹត្តិការណ៍ គេ អ៊ំមានដឹងអារឿងគេ ពេលនឹងមិនមកកំពង់សោមនឹង យើងចាប់ផ្តើមមានព្រឹត្តិការណ៍ ។ ដូចកាលពេលនឹងយើង អឺ វៃជាមួយយួន វៃតាមកោះ តាមអី យួនចាប់ឬទេ កាលនឹងអ៊ំមកដល់កំពង់សោមនូវ?

ធិន : មកហើយ ។

ដានី : មកហើយ អរ ។

ធិន : ឈប់ ។

ដានី : បាទ ។

ធិន : និយាយតិចចុះអានឹងហា ។

ដានី : បាទ ។

ធិន : ដល់មកនៅកំពង់សោមនឹងយូរ អត់ទាន់មានរំដើប រំដួលស្អីទេ, កោះមិនទាន់មានរំដើប រំដួល អីទេ ។ វៃតែម្តុំស្វាយរៀងណ៎ា ស្វាយរៀង មួយជួរ នេះខាងកំពង់យោលនេះ ។ កោះអណ្តែត កោះអី ។ អានឹងយើងក៏វាមានល្បិចបន្តិចដែរ ខ្ញុំនិយាយពិតត្រង់ទៅ ។

បក្សយើងគិតថាគ្រោងការណ៍ ថាយើងរំដោះកម្ពុជាក្រោមវិញ។ បក្សលើកថាយើងត្រូវតែយកដីកម្ពុជាក្រោមវិញ។ ណា!

ដានី : នឹង, អានឹងម៉េចបានអ៊ំដឹង?

ធិន : ហេ អានឹង ពិគ្រោះផ្ទៃក្នុង អានឹង បក្សគេនិយាយផ្ទៃក្នុងស្ងាត់ៗ អានឹងយើងនិយាយស្ងាត់ ប៉ុន្តែខ្ញុំចំហរឲ្យប្អូនឯងដឹង។

ដានី : បាទ។ គេប្រជុំប្រាប់?

ធិន : បាទ!

ដានី : ដូចជាខាងមេ ខាងកងពល ខាងបញ្ជាការកងពល វរៈសេនាធំ វរៈសេនាតូច អ្នកប្រជុំប្រាប់ទាហាន ឬក៏ខាងមេដឹកនាំខាងលើគេប្រជុំប្រាប់?

ធិន : មេខាងលើ។

វណ្ណៈ : មេខាងលើ!

ធិន : បាទ!

ដានី : ហើអញ្ចឹង អ៊ំអីមានបានទៅប្រជុំជាមួយពួកគាត់ដែរ?

ធិន : បាន។

ដានី : ប្រជុំនៅណា?

ធិន : កំពង់សោម។ តា ប៉ុល ពត, តា សុន សេន។

វណ្ណៈ : តា ប៉ុល ពត, តា សុន សេន។

ធិន : បានជួបញ្ចឹក តា ស៊ឺន សេន។

វណ្ណៈ : គាត់ទៅ គាត់ប្រជុំ គាត់និយាយអញ្ចឹង។ អញ្ចឹងប្រជុំប្រាប់ថាយើងវ៉ៃយកកម្ពុជាក្រោមវិញ នឹងប្រជុំឆ្នាំណាទៅ?

ធិន : ទេ, មិនដឹងឆ្នាំប៉ុន្មានទេ។ ប៉ុន្តែអានឹងគ្រាន់តែគេមិនចំហរទេពូ យើងរៀបចំទ័ពផ្តាច់ការព្រោះយើងកាលនោះយើងជាផ្តាច់ការបំរើបក្ស។ ដឹងទេ! ប៉ុន្តែដល់ពេលនោះមក យើងអត់ដឹងថាមានផ្ទៃក្នុងគេបង្កប់ខាងក្នុងទេ។ ពូណា? ពីព្រោះគណៈភូមិភាគក៏ក្បត់។ នៅក្នុងសហករណ៍ក៏ក្បត់ បក្សអត់ដឹងខ្លួនទេ។ បក្សគិតតូតែជាតិ ទ័ពដឹងតែជាតិ, ការពារជាតិ តែប៉ុណ្ណឹងទេ។ ប៉ុន្តែ អាផ្ទៃក្នុងនេះខ្ញុំនិយាយអាផ្ទៃក្នុងនេះកងពលវាក្បត់ ដល់យួនចូលស្រុកនេះ ចូលគិតតែចូលចន្លោះពីផ្លាំងសំពៅមក ខ្ញុំនៅនៅស្ទឹងហាវប្រលោះផ្លាំងសំពៅ។ ពូ អា ប្រលោះផ្លាំងសំពៅចេញពីនេះមកផ្លាំងសំពៅ សារទ្បាងវាឡើងមកនឹង ម៉ោង៨ ម៉ោង១២ ដល់កំពង់សោម។ គិតមើល? ស្រឡាងឡើងមកបានយក

ទៅបញ្ចារអាណាបានបាញ់ៗ ហា បើ វន វេត ក៏ក្បត់ៗ អានេះខ្ញុំនិយាយតែជាក់ស្តែង បើកាំភ្លើងធំចិនឡូមក ផ្ទាក់កាណុងប៉ុនប៉ុននេះ ចូលមួយគ្រាប់ៗ ដាក់មួយគ្រាប់អត់បានទេៗ អត់មានបានបាញ់យួនមួយគ្រាប់ទេ រត់ឯងៗ

វណ្ណៈ : ម៉េចអញ្ចឹង?

ធិន : ចុះយើងមានណាបើក្បត់អស់ហើយនឹង បើក្បត់ៗ

វណ្ណៈ : ក្បត់ក្នុងគ្នាឯងនឹង?

ធិន : បាទៗ បើកងពលក្បត់ហើយនឹង មានពីណាធ្វើម៉េចៗ ក្បត់អស់ហើយៗ

វណ្ណៈ : កងពលក្បត់ ដូចកងពលរបស់អី១៦៤ នឹង អឺ មេកងពលក្បត់?

ធិន : អត់ក្បត់ទេមេកងពល ប៉ុន្តែ អាខាងក្រោមៗ

វណ្ណៈ : អាខាងក្រោម!

ធិន : វរសេនាធំៗ បើអាកងពលដឹងតែនៅខាងក្រោមនោះ មានអីអាវរសេនាធំ អាវរសេនាតូច កងវរសេនាតូច កងវរសេនាធំ ក្បត់អស់ហើយ ហើយយើងមានអីទៀតពូឯងៗ

ដានី : ចុះខ្ញុំចង់បន្តទៀតទាក់ទង, អញ្ចឹងកាលពីបែកនៅឆ្នាំ៧៩ដំបូង នៅខាងតាកែវ នៅខាងនិរតី ខាងកំពង់យោល ខាងពង់អំពិលអីនឹង យើងមានវ៉ៃ អីវ៉ៃយួនមួយសារហើយ?

ធិន : វ៉ៃយួនៗ

ដានី : បាទ, ប៉ុន្តែខាងនឹង ពេលនឹងនៅខាងកំពង់សោមអត់មានទេ?

ធិន : អត់ៗ

ដានី : ដល់អាំទៅរយះពេលប៉ុន្មានបានយើងចាប់ផ្តើមវ៉ៃយក វ៉ៃតាមកោះ យើងវ៉ៃយកកោះ?

ធិន : អត់មានវ៉ៃយកកោះ អត់មានទេៗ ទាល់តែយួនចូលមកកំពង់សោមមក រត់ឯងតែម្តង អត់មានពីណាបានវ៉ៃទេ អត់មានទេៗ

ដានី : អត់ទេ, ខ្ញុំចង់និយាយថាពេលដែលនឹងមិន, អឺមានប្រសាសន៍ដំបូង ពេលនឹងមិនយួនចាប់បាន?

ធិន : ថាយួនចាប់បាន អានឹងឆ្នាំ៧០, ៧៥ទេៗ អាបេសេអេសយើងចាប់ អាទូកយួននោះ អាកប៉ាល់ អាមេរិកកាំងនោះៗ ចាប់កប៉ាល់អាមេរិកកាំងបានយកមកបញ្ឈរនៅកំពង់សោមៗ អាប៉េសេអេស គេហៅអាប៉េសេអេសសុទ្ធតែយួនហើយ ដល់សួរនេះខ្ញុំមិនបានជួបទេណាស់! ចាប់បានហើយ ហើយអាមេរិកកាំងយកអាស្វាបកាត់ទៅទំលាក់នៅកំពង់សោម យើងមិនទាន់បានរៀបចំយោធាទេ ប៉ុន្តែគ្រាន់តែបញ្ជូនយោធាអោយ

ទៅប្រចាំនៅកោះតាង ។ ណាស់! ទៅដល់កោះតាងនឹង យើងអត់ទាន់បានរៀបចំមាន កាំភ្លើងអីគេព័ទ្ធជិត ។ គេឡើងទៅយួននឹងវិតយើងខ្ទេច ។ គ្មានបានតតាំង ។

ដានី : កាលនឹងអ៊ំទៅដល់កំពង់សោមនៅ?

ធិន : ខ្ញុំដល់ហើយ មិននៅឯភូមិទេ ប៉ុន្តែនៅគោកនេះទេ តែយោធានៅឯណោះ ។

ដានី : ពេលអ៊ី ចុះពេលគេចាប់បាន ម៉ាយ្យ៉ាគេស របស់អាមេរិកកាំង កាលនឹងអ៊ំអត់ទាន់បានទៅកោះទេ? អត់បានទៅកោះព្រីងទេ?

ធិន : អត់ទេ ។ ទាល់តែគេលែងខ្មែរមកវិញ បានខ្ញុំបានទៅ ។

ដានី : អ៎! អញ្ចឹង អាពេលដែលអ៊ីវ៉ៃប្រទូសប្រទាស់ជាមួយអាមេរិក ការនឹងហើយ បានមានយើងវ៉ៃជាមួយយួនហើយ ហើយបានយួនចាប់បានកងទ័ពខាងយើង?

ធិន : ចាប់បាននៅកោះតាង ។

ដានី : ចាប់បាននៅកោះតាង! ចាប់នៅកោះតាង ចាប់យកទៅណា?

ធិន : យកទៅដាក់កោះត្រល់នឹង ។

ដានី : ពីកោះតាងទៅកោះត្រល់?

ធិន : បាទ, កោះតាងយកទៅដាក់កោះត្រល់ ។

ដានី : អញ្ចឹងយួនវាវ៉ៃចូលកោះតាង?

ធិន : បាទ ។ យួនវាវ៉ៃចូលកោះតាង ។

ដានី : អ៊ី, អ៊ីខ្ញុំអាចមានប្រសាសន៍កន្លែងនឹងម៉េចបានយួនវាវ៉ៃទៅកោះតាងហើយ វាចាប់! ហ៊ី យ៉ាងម៉េចបានវាដោះលែងវិញ?

ធិន : អានឹងគេ មកថាមករំដោះ ប៉ុនអា ម៉ាសេអេសនឹង ។ អា ប៉ុន សេអ៊ីអា របស់អាមេរិកនឹង ។

ដានី : អាម៉ាយ្យ៉ាគេសនឹង?

ធិន : បាទ ។

ដានី : យួនវាវ៉ៃចូលមក មិនមែនអាមេរិកកាំងវ៉ៃទេ វ៉ៃយួនទេ?

ធិន : យួន មិនមែនអាមេរិកកាំងមកណា ។

ដានី : អញ្ចឹង ។ យួនវ៉ៃហើយវាចាប់ វាចាប់កងទ័ពយើងច្រើនទេ?

ធិន : មួយវរសេនាតូច ទាល់តែអាសុងមិនដឹងទៅណាហើយទេ ។ ទាល់តែសួរអាសុងមើល?

ដានី : បាទ ។

ធិន :	មួយវរសេនាតូចចាប់ទៅនៅនឹង ។ អានឹងបានដល់ អានេះខ្ញុំនិយាយទៅ ដោយសាររួចនឹងមក ថាសម្តេចយើងស្រែកមកពីណាទេ ខ្ញុំមិនបានស្តាប់ដែរ ។ សម្តេចស្រែកថាត្រូវតែលែងកូនចៅលោកវិញ ។ បើថាមិនលែងទេលោកមិនសុខចិត្តម៉េច ។

ដានី :	សម្តេចឪ?

ធិន :	បាទសម្តេចឪ ។

ដានី :	សម្តេចឪស្រែក?

ធិន :	បាទ ។

ដានី :	កាលនឹងអ៊ំទៅ នៅកំពង់សោមនៅឡើយទេ? នៅកន្លែងជិត ។

ធិន :	នៅភូមិថ្មីខាងចំការដូងចេងហេងនឹង ។

ដានី :	នឹង មិនទាន់បាននៅកោះទេ?

ធិន :	បាទ ។

ដានី :	ហឺ ដល់ហើយមកបានគេប្រលែងមក អឺ យួនប្រលែងមកវិញ?

ធិន :	បាទ ។

ដានី :	ប្រលែង ប្រលែងមក?

ធិន :	នឹងមកនៅ ពួកនឹងមកនៅកោះតាងវិញដដែលនឹង ។

ដានី :	មកនៅកោះតាងវិញដដែល! អ្នក អ្នកដែល

ធិន :	យួនចាប់ទៅចាប់ទៅមកនៅកោះតាង ។

ដានី :	យួនចាប់ទៅមកនៅកោះតាង ។ ហើយអ៊ំគេបញ្ជូនទៅនៅកោះព្រីង?

ធិន :	បាទ ។ ទៅរៀបចំនៅកោះព្រីងវិញ ។ ហើយកោះប៉ូឡូវៃ អានឹង៦២ នឹងមិនដឹងគេបញ្ជូនវរសេនាតូចលេខប៉ុន្មានទៅនេះ! ៦២ នេះទៅនៅកោះប៉ូឡូវៃ ។

ដានី :	៦២នេះទៅនៅកោះប៉ូឡូវៃដែរ?

ធិន :	បាទ ។ ប៉ុន្តែមិនដឹង អឺ លេខកងពលប៉ុន្មាន ។ មិនដឹង ទាល់តែសួរអាសុងបានដឹង ។ពីព្រោះវាកងពលវរសេនាធំមួយៗ វាមានបីកងវរសេនាតូច អញ្ចឹងវាមិនដឹងកងវរសេនាតូចណាទៅនៅឯនឹង ។

ដានី :	បាទ, អញ្ចឹង អឺ អ៊ំនៅកោះព្រីងបានយូរប៉ុទេ?

ធិន :	នៅបានយូរខែដែរ បី បួនខែមិនដឹងពូ ក្មួយ! រៀបចំដាំត្រលាច ដាំត្រសក់ ដាំអីផ្សេងៗ ប៉ុនៗនេះ ។ ផ្ទៃតែមួង ដាក់ទៅផ្ទៃតែមួង ។ បើត្រប់យើង អាត្រប់ វែងៗនឹងប៉ុនប៉ុននឹងដាក់ទៅផ្ទៃតែមួង ។ គ្រាន់តែកំសត់ទឹក ។ ផ្ទុតទឹកសុទ្ធទឹកបាទ ។

ដានី : អត់មានទឹកសាប?

ធិន : មាន មានតែមួយអាង ។ យើងទៅរកឃើញមានមួយអាងមានតែទឹកមួយអាង ក្រៅពីនឹងអត់មានទេ ។

ដានី : ហឺ, ចុះអ៊ំពេលដែលយើងនៅកោះព្រីងនឹង មានជួបព្រឹត្តិការណ៍អ្វីខ្លះដែរ?

ធិន : អត់ ។

ដានី : អត់ទេ!

ធិន : អត់, អត់មានអីទេ ។

ដានី : នៅបី បួនខែនឹង នៅទទេ អត់មានព្រឹត្តិការណ៍ អត់មានអី? ។

ធិន : អត់ អត់មានអីទេ ។

ដានី : ហឺ, ហឺ ដល់ពេលចេញពីកោះព្រីង ទៅណាទៀត?

ធិន : មកនៅកន្លែងចំការដូងចេងហេងវិញ ។

ដានី : ត្រលប់មកចំការដូងចេងហេងវិញ?

ធិន : មកកន្លែងដើមវិញ ។

ដានី : មក ។ ចុះអ៊ំមានដឹងថាមូលហេតុអ្វី បានគេបញ្ជូនក្រុមអ៊ំទៅខាងកោះព្រីងនឹង?

ធិន : ទៅការពារ ។

ដានី : ទៅការពារ ។

ធិន : ដឹងតែទៅការពារនឹង ។

ដានី : បាទ ។ ហឺ បន្ទាប់ពីគេដកក្រុមអ៊ំមកចំការដូងចេងហេងវិញ គេដាក់ក្រុមណាទៅវិញទៅ?

ធិន : ក្រុម៦២ ដដែល ។

ដានី : ក្រុមវរសេនាធំ៦២ នឹងទៅកោះព្រីងវិញ ។

ធិន : ប៉ុន្តែមិនដឹងកងលេខប៉ុន្មានអីប៉ុន្មានទេណា! ប៉ុនគ្រាន់តែដឹងថាកងវរសេនាធំគេទៅនឹងវិញ ។ ហើយខ្ញុំមកនៅកោះ នៅចំការដូងចេងហេងនឹងវិញបានប្រហែលមួយអាទិត្យ ។ ទៅនៅនឹងមួយអាទិត្យគេបញ្ជូនទៅរ៉ុងក្នុង ។

ដានី : បាទ, ចឹងមកហើយ បានមកខាងរ៉ុងខាងក្នុងវិញ?

ធិន : បាទ, រ៉ុងក្នុង ។

ដានី : ទៅធ្វើអីនៅរ៉ុងក្នុងនឹង?

ធិន : ទៅការពារកោះនឹងដែរ ។

ដានី : ទៅការពារកោះនឹង ។ កោះរ៉ុងក្នុងនឹងឆ្ងាយឬទេ?

ធិន ៖ ចេញទៅមើលទៅដែកំពង់សោមទៅ មើលទៅឃើញហើយ ។

ដានី ៖ ជិតនឹងដែរ?

ធិន ៖ បាទ, មើលទៅឃើញហើយ ។ មើលទៅរុងនឹងធំតែម្តង ។

ដានី ៖ ធំ ហី ធំ!

ធិន ៖ បាទ ។ ដើរមួយថ្ងៃអត់ជុំទេ ។ រុងក្នុងដើរមួយថ្ងៃអត់ជុំទេ ។

ដានី ៖ ហី ពេលមកដល់រុងក្នុងនឹងអត់មានពិបាកទេ ?

ធិន ៖ ធម្មតា ពិបាកធម្មតា ។ យើងមិនដឹងធ្វើម៉េច បើពិបាក ពិបាកទៅ ។

ដានី ៖ មាន ទឹក ។ ដូចចង់និយាយថាទឹកហូបចុកអី!

ធិន ៖ ទឹកមិនខ្វះទេ ។ វាធំធ្វើស្រែបាន ។

ដានី ៖ ធ្វើស្រែលើនឹងបានទៀត?

ធិន ៖ បាទ, បាន ធ្វើស្រែ ធ្វើស្រែបានទាំងអស់ ។ មួយជួរនឹងធ្វើស្រែបានទាំងអស់ ។ ប៉ុន្តែ អាម៉ានាស គេហៅថា ម្នាស់ ម្នាស់ ម្នាស់ យើងទៅដល់នឹងដូងក៏ច្រើន ។ ម្នាស់ក៏ច្រើន ដែរ ។ ចង់យើងហូបប៉ុន្មានក៏ហូបទៅ ជាយោធា ។

ដានី ៖ ហី, កាលនឹងយើងដាំខ្លួនឯង?

ធិន ៖ អត់ទេ, របស់ចាស់ ។

ដានី ៖ ចាស់ពីមុនមក ។

ធិន ៖ ប្រជាជន ប៉ុន្តែយើងមិនដឹងមកនៅតាំងពីកាល ។

ដានី ៖ ប៉ុន្តែ ពេលដែលអ៊ំទៅនៅនឹង ប្រជាជនទៅនៅអត់?

ធិន ៖ អត់មានទេ អត់មានទេ មានតែជាយោធាតែម្តង ។

ដានី ៖ ហី, ហីពេលដែលទៅនៅកោះរុងក្នុងនឹង អត់មានព្រឹត្តិការណ៍អី? អត់ដែរ?

ធិន ៖ អត់ ។ ដឹងតែធ្វើ ដឹងតែនេះ យើងមករៀន រៀននៅកំពង់សោមទាំងអស់គ្នាអញ្ចឹង ទៅណាស់ ។

ដានី ៖ មករៀននៅកំពង់សោមដែរ!

ធិន ៖ បាទ ។ មករៀននៅកំពង់សោម ។

ដានី ៖ កាលនឹងអ៊ំមានតួនាទីអ្វីដែរ?

ធិន ៖ ខ្ញុំ កងហា ។

ដានី ៖ កងហា ណា ។

ធិន ៖ បាទ ។

ដានី ៖ ហឺ, កាលនឹងកងហ យើងមានកំលាំងច្រើនដែរ?

ធិន ៖ នែក មានបើគិតទៅបីក្រុមដែរ ។

ដានី ៖ បីក្រុម ។

ធិន ៖ ១២នាក់បើគិតទៅ ។

ដានី ៖ ១៣, ១២នាក់ គុណនឹង ៣ ។ វា ៣៦ ជិតខ្ទង់ ៤០នាក់អីដែរ ។

ធិន ៖ បាទ ។

ដានី ៖ ហឺ ។ ហឺ ពេលប្រជុំនៅកំពង់សោម ខស្សាហ៍មកប្រជុំដែរ ។

ធិន ៖ អោយតែមក កោះហៅរហូតនឹង ប៉ុន្តែគេរើសមើលដែរណាតូ មិនមែនចេះតែយកមករើស យើងអត់មាននិន្នាការ ។

ដានី ៖ អត់និន្នាការ ។

ធិន ៖ អត់មាននិន្នាការ ជាប់ជំពាក់វាក់វិនអី បងប្អូនគេសួរប្រវត្តិរូបពីនេះទៅណា! ពីបងប្អូនទៅពីម៉ែឪទៅ ម៉ាមីង អី បើថាអត់អានឹងបានគេហៅមករៀនសូត្រ ។ ដឹងទេ! បើថាយើងមានជាប់សេអ៊ីអា មានជំពាក់វាកវិន អី គេមិនទេ ។

ដានី ៖ បាទ ។ ហឺ អឺ អឹមកកងហ អញ្ចឹង ពេលយើងមកប្រជុំ មកប្រជុំជាមួយថ្នាក់អីគេ? អឺ ថ្នាក់ អឺ?

ធិន ៖ កងពលក៏មាន វរសេនាតូចក៏មាន មជ្ឈិមក៏មាន ។

ដានី ៖ មជ្ឈិមក៏មានមកដែរ?

ធិន ៖ បាទ ។

ដានី ៖ ខស្សាហ៍ទេ ប្រជុំ?

ធិន ៖ ប្រជុំមក បី បួនខែអញ្ចឹងទៅ ។ ប្រជុំគេមិនហៅយើង យើងមិនបានមក ជួបជុំ ។

ដានី ៖ មកជួបជាមួយថ្នាក់កងពលញឹកញាប់ដែរ? រយៈពេលប៉ុន្មានប្រជុំមួយដង ប្រជុំជាមួយកងពល?

ធិន ៖ ៣ខែ

ដានី ៖ ៣ខែមួយដង ។

ធិន ៖ បាទ ។

ដានី ៖ ហើយប្រជុំថ្នាក់កងពលប្រជុំជាមួយគណៈកងពលដូច តាមុត, តាសារឿន, តាង៉ែត អីនឹង?

ធិន ៖ បាទ ។ លើតែផែនការណ៍រឿងយើងទៅការពារទឹកដី ការពារជាតិ ការសាសនា ការពារដូចជាកុំឲ្យ ។

ដានី ៖ ហ៊ឺគេមានរៀបផែនការណ៍ថាយើងត្រូវវ៉ៃយកកោះ? កោះខ្មែរយើងពីមុនមក ដូចជាកោះត្រល់ កោះអីនឹងយើងត្រូវវ៉ៃយកវិញអត់?

ធិន ៖ អានឹងកាលនោះវាអត់មានពីណាឈ្វានពាន ។ អត់មានអាណាទេ កោះត្រល់អីនៅ អត់មានអារឿងអីប៉ះពាល់អីទេ ។ យើងគិតមួយតែពីរំដោះជាតិ រំដោះកម្ពុជាក្រោម ។ និយាយទៅប្រាប់តែពីរឿង ។

ដានី ៖ រំដោះជាតិ រំដោះកម្ពុជាក្រោម ។ ប៉ុន្តែកាលជំនាន់នឹង មុននឹងអ៊ំមានប្រសាសន៍ថាយួនវាមិនវ៉ៃចូលយកកោះតាង ហើយវាចាប់បាទទាហានយើងមួយវរសេនាតូចនៅកោះតាង ហើយចាប់ពីកោះតាងយកមកដាក់នៅកោះត្រល់!

ធិន ៖ បាទ ។

ដានី ៖ បាទ ។ អញ្ចឹងកោះត្រល់មិនយួនអ្នកគ្រប់គ្រង?

ធិន ៖ យួន ប៉ុន្តែអត់ហ៊ានថាទេ ។

ដានី ៖ ប៉ា!

ធិន ៖ អត់ទានហ៊ានថារំដោះទេ ។

ដានី ៖ អត់ទាន់ទេ!

ធិន ៖ បាទ ។ យើងទាមទាឲ្យតែលែងទ័ពយើងមកវិញ ។ ពីព្រោះយើងមិននិយាយអារឿងវ៉ៃអារឿងអីនឹងទេ ពីព្រោះគេមិននិយាយខ្វះខ្វាយអីទេ គេនិយាយស្ងាត់ណាពូណា ។ យើងទៅនិយាយថា យើងទៅវ៉ៃអីយកកោះត្រល់វិញ យួនកំលាំងវាច្រើនជាងយើង ។ ដឹងទេ? ពីព្រោះគេ បើយើងដឹងថាមានផ្ទៃក្នុងក្បត់ យើងក៏មានក្បត់ដែរយើងបែកការ ។ លាក់ការណ៍ ។ ប៉ុន្តែគ្រាន់តែទៅប្រជុំទៅយកទឹកដីយើង កម្ពុជាក្រោមតែប៉ុណ្ណឹង ។ វ៉ៃថ្ងៃណា អីថ្ងៃណាគេមិនប្រាប់យើងទេ ។

ដានី ៖ បាទ ។ ហ៊ឺ, ដល់ពេលអ៊ំទៅនៅអី រ៉ុង កោះរ៉ុងក្នុងនឹង នៅបានរយៈពេលប៉ុន្មានឆ្នាំដែរ?

ធិន ៖ ៦ខែ ។

ដានី ៖ ហ៊ឺ, នៅ៦ខែនឹង យើងអត់មាន ។

ធិន ៖ រៀន ហាត់ ។

ដានី ៖ យួនអី វាអត់ដែលមានមកឈ្វានពានអីទេ?

ធិន ៖ នៅឆ្ងាយណាស់ ។ អត់ទេ អត់ទេ ។

វណ្ណៈ ៖ ឆ្ងាយហើយ ។ ចុះយួនអីវាចង់រត់ឆ្លងដែនទៅថៃ ទៅអីនឹងមានឆ្លងកាត់តាមនឹងទេ?

ធិន ៖ អត់ទេ ។

ដានី ៖ អត់ទេណោះ! អ៊ំពេលដែលអ៊ំនៅកោះរុងបាន៦ខែហើយទៅណាទៀតទៅ?

ធិន ៖ មកនៅស៊ឹងហាវ ។

ដានី ៖ មកនៅស៊ឹងហាវវិញ ។ ឆ្នាំប៉ុន្មានទៅ មកនៅស៊ឹងហាវហ្នឹង?

ធិន ៖ អេ ឆ្នាំប៉ុន្មានទេពូ! ស៊ឹងហាវភ្លេចហើយ ។

ដានី ៖ អញ្ចឹងដកមកពីនឹងមក មកស៊ឹងហាវ?

ធិន ៖ បាទ ។

ដានី ៖ ស៊ឹងហាវនឹងកន្លែងអីទេ?

ធិន ៖ ស៊ឹងហាវមកធ្វើ នៅដែលាក់ ។

ដានី ៖ អានឹងគេធ្វើដៃថ្មីទៀត?

ធិន ៖ បាទ ។ ចិនមកធ្វើ ។

ដានី ៖ ចិនមកធ្វើ! ហ៎ី អឺ អ៊ំនៅកាន់ខាងកាំភ្លើងធំដីដែល ឬមកខាង?

ធិន ៖ នៅខាងកាំភ្លើងធំដីដែល ។

ដានី ៖ អញ្ចឹង កាំភ្លើងធំ យើងមកដៃធ្វើអ្វី?

ធិន ៖ មកធ្វើដៃ ។

ដានី ៖ មកធ្វើដៃ?

ធិន ៖ បាទ ។ កាំភ្លើងមានតែយើង មិនមានទៅធ្វើសង្គ្រាមមកពីណា ។ មកធ្វើដៃ ។ ក្នុយទៅដល់ស៊ឹងហាវនឹង ទៅឃើញចាក់ទំនប់រលក បានប្រវែងប្រហែល២០០ម៉ែត្រ ចេញពីនេះនឹង ខ្ញុំធ្វើហើយនែក ។

ដានី ៖ អានឹងអ៊ំជាអ្នកធ្វើ!

ធិន ៖ បាទ, កងខ្ញុំធ្វើនៅនឹង ។

ដានី ៖ កង អ៊ំធ្វើនៅនឹងតែកងអ៊ំ ឬមានគេផ្សេងមកច្រើនទៀត?

ធិន ៖ បី បី អឺ មួយវរសេនាតូចទៀត ។

ដានី ៖ មួយវរសេនាតូចទៀត!

ធិន ៖ បាទ, ប៉ុននឹង១៣ ។

វណ្ណៈ ៖ ១៣ ហ៎ី?

ធិន ៖ បាទ ។

ដានី ៖ កងវរសេនាតូចរបស់ កងវរៈសេនាធំ៦១នឹងដែរ?

ធិន ៖ បាទ, ប៉ុននឹង១៣ កងវរៈសេនាតូចគេ១៣ ណាស់ ។

ដានី ៖ ហឺ, ហើយយើងធ្វើយ៉ាងម៉េចទៅពូ? ពីព្រោះកំពង់ផែត្រូវធ្វើធំណាស់ ។

ធិន ៖ ឡានចិននឹង ។

ដានី ៖ ឡានចិន ។ គេដឹកអី ដូចថាដឹកថ្មដឹកអី មកពីណាមកមកចាក់?

ធិន ៖ យើងខ្លួននូវនឹង ។ ក្អួយទៅឃើញហើយ នៅនៅអាកោះនឹង មើលពីខាងនេះទៅឃើញអាកន្លែងដុតថ្ម កន្លែងវៃថ្ម ។ ដឹកអាថ្មធំៗ ដឹកពីឆ្ងាយទៅ មិនដឹងគេយកពីណាទៅណា! អានឹងឃើញគេដឹកយកទៅចាក់ ចាក់ហើយយើងយកអាថ្មតូចៗចាក់ពីលើ ។

ដានី ៖ យើងយកអាធំៗដឹកដាក់ទៅ ហើយដាក់ពីលើទៀត ។ ពីណាអ្នកគ្រប់គ្រងនូវនឹង? កន្លែងនឹង?

ធិន ៖ ភាព ។

ដានី ៖ ភាព!

ធិន ៖ បាទ ។

ដានី ៖ ឈ្មោះភាពនឹងជាអ្នកគ្រប់គ្រង?

ធិន ៖ បាទ ។

ដានី ៖ គាត់នៅឬទេ?

ធិន ៖ គាត់ស្លាប់បាត់ហើយ ។ ភាព ឡើងកងពលក្រោយជាមួយ តាមុត ។

ដានី ៖ ហឺ, ភាពនឹងគាត់ឡើង ណេស?

ធិន ៖ បាទ, កងពល ។

ដានី ៖ ចុះតា ប្អូន តាមុត នោះឈ្មោះតា? គាត់នៅនឹងដែរឬអត់ទេ? តា អីទេ តាអ៊ឹម ។

ធិន ៖ តាអ៊ឹមខាងសេដ្ឋកិច្ច ។

ដានី ៖ ខាងសេដ្ឋកិច្ច ។

ធិន ៖ បាទ ។

ដានី ៖ ប៉ុន្តែគាត់មានមកនៅខាងកំពង់ផែនឹងដែរអត់ទេ?

ធិន ៖ អត់ទេ ។

ដានី ៖ អត់ទេ ។

ធិន ៖ នៅគាត់កាន់ភស្តុភារ ។

ដានី ៖ ភស្តុភារបស់កងពល?

ធិន ៖ បា៉ទ ។

ដានី ៖ ហឺ, មកធ្វើខាងកំពង់ផែនឹងដូចមានអ្នកសមាសភាពអីវ៉ាមិនល្អអីមកធ្វើនៅនឹងដែរ ឬអត់?

ធិន ៖ មានទាំងអស់ ។

ដានី ៖ មានទាំងអស់?

ធិន ៖ ៦០, មើល ១៤ ហឺ ១៩, ១៧, ១៨ ។

ដានី ៖ ១៨នៅហ្នឹង?

ធិន ៖ បាទ! មកធ្វើនៅហ្នឹងទាំងអស់ ។

ដានី ៖ អ៊ំនៅកំពង់ផែនឹងមានផ្លាស់ទៅកោះអីផ្សេងទៀតដែរ ឬអត់ទេ?

ធិន ៖ អត់ទេ យួនចូលមក ។

ដានី ៖ នៅកំពង់ផែនឹងទាល់តែយួនចូលតែម្តង?

ធិន ៖ នៅទាល់តែយួនចូល ។

ដានី ៖ ដូចជាកោះផ្សេងៗ ដូចជាកោះតាង កោះប៉ូឡូវ៉ៃ អីមានដឹងថាស្ថានភាពអីយ៉ាងម៉េចដែរពេលនឹង?

ធិន ៖ អត់ ។

ដានី ៖ មាន ដូចថាយួនវ៉ាមក វ៉ាចូលមកមានដូចថាវ៉ាវ៉ៃ ឬក៏អីយ៉ាងម៉េចអីទេ?

ធិន ៖ អត់មានបានវ៉ៃទេ ។ ខ្មែរក្រហមអត់មានបានវ៉ៃ ។ មួយគ្រាប់ក៏មិនបានវ៉ៃផង ។ វ៉ៃមានតែនៅជើងទឹក ជើងគោកនៅកងកេង, រៀម នឹងបានវ៉ៃគ្នាអានឹងហា ។ នៅកងកេងនៅរៀមនឹងបានវ៉ៃគ្នាអានឹងហា ។ បើជើងទឹកអត់មានពីណាបានវ៉ៃអីទេ ។ រត់ចោលទាំងអស់ ។

ដានី ៖ ដែលពេលដែលយើងធ្វើព្រលានយន្តហោះអីនៅស៊ីងហាវអី, អោ ប្រលំធ្វើកំពង់ផែនៅស៊ីងហាវនឹង កាលនឹងយ៉ាងម៉េចដែរស្ថានភាព ពេលដែរប្រៀបធៀបដែលអ៊ំនៅកោះហើយនៅស៊ីងហាវខុសគ្នាយ៉ាងម៉េចទៅ?

ធិន ៖ ដូចតែគ្នានឹង ។ ដូចខ្ញុំថាដូចតែគ្នានឹង អត់មានអីខុស ។ យ៉ាងនៅជាយោធា គេអត់មានអោយមានជួបនារីផងនឹង ដូចតែគ្នា ។

ដានី ៖ អញ្ចឹង កាលនឹងអ៊ំមានរៀបការនៅ?

ធិន ៖ នៅ ។

ដានី ៖ អត់ទានទេនោះ!

ធិន ៖ បាទ ។

ដានី ៖ ចុះនៅកន្លែងនឹងទបមារថាយើងធ្វើការងារ ឬក៏មានយើងធ្វើខុសអី យ៉ាងម៉េចៗអី យ៉ាងម៉េចដែរ?

ធិន ៖ គេដកតែប៉ុណ្ណឹង ។

ដានី ៖ គេដក គេដកទៅណា?

ធិន ៖ គេដកតាមទោសយើងទៅ គេដកមកដាក់នៅ១៧ក៏មាន នៅ១៨ក៏មាន, ១៩អាហ្នឹងដាច់

ដានី ៖ ដាច់គុក ។

ធិន ៖ អានឹងវាអស់សមត្ថភាព ។ វានឹងគេថាបក្សលែងទុកចិត្ត ។

ដានី ៖ លែងទុកចិត្តហើយ?

ធិន ៖ បាទ ។

ដានី ៖ វាមានកង ដប់ប៉ុន្មាន?

ធិន ៖ ១៧, ១៨ ។

ដានី ៖ ១៧, ១៨ ។

ធិន ៖ ១៧ មួយយប់អានឹងនៅសកម្មណា, ១៨ មធ្យម, ១៩ អស់ ។

ដានី ៖ ១៩ អស់ហើយ! អស់ហើយគេមានយកមកដាក់គុកដែរអត់?

ធិន ៖ អត់មានដាក់គុកទេនៅតែកន្លែងនឹងគេឲ្យហូបបាយ គេឲ្យធ្វើការតាមទោសយើង ។

ដានី ៖ ហឺ មានកន្លែងគុកគេឬអត់?

ធិន ៖ អត់មានកន្លែងគុកទេ ។

ដានី ៖ អត់មានទេ ណ៎?

ធិន ៖ អត់មានទេ, អត់មានគុកដាក់ទេ ។

ដានី ៖ អត់មានទេ ។ ចុះអ៊ំពេល អ៊ំអត់បានទៅកោះប៉ូឡូវ៉ៃទេ?

ធិន ៖ អត់ ។

ដានី ៖ អត់ដែលទៅទេ!

ធិន ៖ អត់ទេ ។ ខ្ញុំបានតែកោះព្រីងហើយនឹងកោះតាង រ៉ុងក្នុងតែប៉ុននឹងទេ ។ ប៉ុន្តែគ្រាន់តែដឹងថាកោះ គ្រាន់តែជិះកាណូត ជិះអីទៅជិតនឹង យាមទៅណា បានតែយាមទេ ។

ដានី ៖ ហឺ, កោះតាងអ៊ំធ្លាប់ចូលទៅ?

ធិន ៖ បាទ ។ កោះតាងចូល ។

ដានី ៖ កោះតាងយ៉ាងម៉េចដែរពេលអ៊ំចូលទៅ? ទៅនៅយូរឬទេ?

ធិន :	អត់បាននៅទេ។ ឡើងទៅលេងមួយម៉ោង ពីរម៉ោងនឹង ដូចយើងទៅធ្វើទស្សនៈកិច្ច នៅដើងដើងកោះនឹងណា។ គ្រាន់តែថាកោះព្រីងខ្ញុំបានទៅ ហើយកោះស្តេចខ្ញុំបានទៅ ឡើងទៅប្រចាំការ មួយអាទិត្យអញ្ចឹងទៅមួយដង ទៅមើលកោះអញ្ចឹងទៅណា។ យើងអត់បានទៅនៅនឹងជាប់ជួនទេ។ គេមានអង្គភាពគេ ដូចថាឥឡូវ មួយវរសេនាតូច មួយអាទិត្យចឹង កងក្មួយអញ្ចឹងទៅមួយថ្ងៃ ពីរថ្ងៃ ដើរមើលតាមកោះយើងអញ្ចឹងទៅ។ ដូចខ្ញុំ មួយថ្ងៃ ពីរថ្ងៃ ទូកពីនេះទៅគេឲ្យទៅមើលកោះ ទៅមួយថ្ងៃអញ្ចឹងទៅ វិលមកកន្លែងវិញតែប៉ុននឹងទេ។ អត់មាន។

ដានី :	អត់ អត់បាននៅទីនេះទេ?

ធិន :	អត់ទេ។

ដានី :	ហឺ ខាងថ្នាក់ដឹកនាំ ដូចថាខាងកងពល អី គេធ្លាប់ទៅតាមកោះដែររឺអត់ទេ?

ធិន :	កងពលគេទៅមួយដង មួយដង។

ដានី :	មួយដងៗ។

ធិន :	ទៅវរសេនាធំ។

ដានី :	វរសេនាធំ ហឺ!

ធិន :	បាទ។ កងពលតាមុត មិនបានទៅទេ។

ដានី :	អត់ទៅទេ។

ធិន :	ទៅ ទៅតាង៉ែត។

ដានី :	តាង៉ែត ណ៎!

ធិន :	តាង៉ែត។

ដានី :	ហឺ អញ្ចឹង អ៊ឹមកនៅដែស៊ឹងហាវនឹងនៅយូរ?

ធិន :	នៅដល់តែគេធ្វើថ្នល់រទះភ្លើងហើយ។ ខ្ញុំនៅកំពង់សោមនឹងទាល់តែធ្វើថ្នល់ទេះភ្លើងហើយ អីហើយ ធ្វើដល់ត្រពាំងពោធិ៍។ យើងនៅកំពង់សោមនៅធ្វើនឹងធ្វើចេញពីនឹងទៅ។

ដានី :	ចុះអ៊ំ អឺក្នុងនឹងយើងមានបានឡើងឋានៈ អីទៀតអត់?

ធិន :	អត់ទេ។

ដានី :	នៅតែកងហាដដែល។

ធិន :	កងហា។ គេមិនងាយឲ្យឡើងទេ។ មិនងាយឡើងទេ។ ដូចយើងមិនសូវចេះអក្សរ មិនសូវអែបអបផងនៅនេះ ដូចថាយើងអត់មានខ្សែអីនឹងគេ។

ដានី :	អ៊ំដល់ពេលយួនវៃចូលមក៧៩ នឹងធ្វើម៉េចទៀត?

ធិន ៖ ខ្ញុំរត់មកអត់មានបានវ៉ៃទេ។ មក មក។

ដានី ៖ រត់ពី?

ធិន ៖ មកពីស៊ីងហាវ មកនៅទ្រា មកនៅរោងចក្រទ្រា ផ្លូវទៅ នេះរោងចក្រទ្រា ពីផ្លូវជាតិលេខ៤ នេះទៅ។ អាចមកកោះកុងនេះ អាផ្លូវទ្រានឹង។ រោងចក្រ ទ្រានឹងបានជួបតាសេង តាសេងឲ្យពាក់កាំភ្លើងនឹងទៅវិញ។

ដានី ៖ តាសេង គាត់នៅដើងទឹកដែរនឹង?

ធិន ៖ បាំ។ នៅកោះកុងដែរឥឡូវនឹង ជាមួយតាមុត។

ដានី ៖ តាសេង!

ធិន ៖ តាសេង នៅកងពលដែរ។

ដានី ៖ តាសេង កងពល!

ធិន ៖ បាទ។

ដានី ៖ បាទ។ ហឺ ដល់ពេលពីទ្រានឹង អឺ អ៊ំគេចាប់ផ្ដើមពាក់កាំភ្លើងថ្មីទៀតដែរ?

ធិន ៖ បាទ។

ដានី ៖ ហឺ, អ៊ំនៅក្នុងកងពលណាវិញទៀត?

ធិន ៖ នៅ៦៤ ដដែល។

ដានី ៖ នៅ៦៤ ដដែល! បាទ, ហឺ ពីទ្រានឹងមកណាទៀត?

ធិន ៖ មក លូជួងតូ ទៅមកវាលរេញ។

ដានី ៖ មកវាលរេញ។

ធិន ៖ ត្រពាំងអំពៅ។ មកវាលរេញ មកវ៉ៃគ្នានៅនឹង។

ដានី ៖ វ៉ៃនឹងយូរអីទេ?

ធិន ៖ វ៉ៃយូរដែរ វ៉ៃយូរ។

ដានី ៖ បាទ។ ហើយយ៉ាងម៉េចទៀតទៅអ៊ំ?

ធិន ៖ វ៉ៃហើយ ទៅនៅត្រពាំងអំពៅ។ ត្រពាំងអំពៅនៅស្ពានកំពុងស្លាប់នឹងណា។ ត្រពាំងអំពៅនឹង យួនទាក់វ៉ៃចង្រ្គានបាយពីក្រោយ។ វ៉ៃពីមុខវាមិនឈ្នះចាញ់ទេ វ៉ៃពីមុខ។ ប៉ុន្តែគេមានកំលាំងបន្កប់ពីក្រោយ មកវ៉ៃផ្ទះបាយយើងហើយ យើងនឹងរត់។

ដានី ៖ បាទ, រត់មកណាវិញ?

ធិន : រត់មកអញ្ជឹងមក រលាក់កង់ជើង មកចេះមក មកត្រែងត្រយឹង នៅត្រែងត្រយឹងអញ្ចេះៗ រលាក់កង់ជើង យើងមកចេះ មកឡើងកំពង់ដែ មកកោះកុងនេះៗ ស៊ីងអាវែងនេះៗរត់មកអញ្ជឹងមក មកឆ្លង ចូលមកឆ្លងវាលវែងៗ

ដានី : បាទ វាលវែងៗ

ធិន : ចាំ វាលវែង, ចូលមកថៃ នៅខ្វងយៃៗ

ដានី : ចូលថៃ ឆ្លងមកខ្វងយៃៗ

ធិន : ចាំៗ

វណ្ណៈ : ចាំៗ ហើយម៉េចទៀតទៅ?

ធិន : រត់មក ចេញពីនឹងមក ថៃគេជូនមក នេះតាងនេះៗ

ដានី : ចាំ?

ធិន : ត្រាង-ឡែមៗ

ដានី : ត្រាង-ឡែម នេះវិញៗ

ធិន : បាទៗ

ដានី : ហឺ នឹងអ៊ំនៅកងពលដដែល ឬក៏ផ្លាស់ប្តូរដែរ?

ធិន : នឹងលែងមានកងពលហើយៗ

ដានី : អញ្ជឹងៗ ហឺ អ៊ំរៀបការកាលណាទៅ?

ធិន : អូ, រៀបការ មិនដឹងកាលណាហើយទេ! ៨០ៗ ទាល់តែមកនូវនេះ មើល ៧៩, ៧៩ឡើងទៅនៅៗ មកអត់បាយ ងាប់ច្រើនពេក គេបញ្ជូនទៅស្រះកែវៗ ទៅរៀបប្រពន្ធនៅស្រះកែវៗ រៀបប្រពន្ធបាននៅស្រះកែវ មកវិញបានទៅនៅភូមិដូងនោះ ប្រពន្ធឆ្លងទន្លេហើយស្លាប់ៗ

ដានី : ភូមិដូង-ម៉ាឡៃហ្នឹង?

ធិន : បាទ! ដើរទៅលើដើមឈើស្លាប់ៗ ស្លាប់ទៅបានទៅរៀបប្រពន្ធក្រោយនេះនៅ នេះបីងត្រកួននេះៗ

ដានី : បីងត្រកួន!

ធិន : បាទៗ

ដានី : អ៊ំនៅជាកងទ័ពដដែល ឬក៏ឈប់ហើយ?

ធិន : ឈប់ហើយៗ

ដានី : ឈប់ ឈប់ពីឆ្នាំណា?

ធិន ៖ ខ្ញុំការហើយ ឈប់តាំងពីផ្តាច់ខ្លួនមក ។ គេឲ្យទៅវៃខ្មែរទៀត ។

ដានី ៖ អឺ ប៉ុន្តែមុនផ្តាច់ខ្លួននឹង អ៊ំនៅក្នុងកងពលណា?

ធិន ៖ នៅកងពល៦៨ដដែល ។ នៅជាមួយតាកននេះ ។ ៦៨ ។

ដានី ៖ តាកន!

ធិន ៖ ចា៎ ។

ដានី ៖ នៅជាមួយតាកនវិញ?

ធិន ៖ ចា៎ ។

ដានី ៖ អញ្ចឹងកាលពីមុនមកនៅជាមួយតាសេង ហេ?

ធិន ៖ ដល់ពេលមកនៅកោះនោះ បានមកនៅជាមួយ ។

ដានី ៖ បាទ, អញ្ចឹង នៅជាមួយតាសេងនេះរហូតដល់ឆ្នាំណាបានឈប់ នៅជាមួយតាសេងមកនៅជាមួយតាកនវិញ?

ធិន ៖ ទាល់តែរត់មកនេះ ។ រត់មកនេះបានគេរៀបកង៦៨នេះ ។

ដានី ៖ អូរ, អញ្ចឹងរត់ពីកន្លែងតាសេងមក មកនៅនេះវិញ?

ធិន ៖ បាទ ។

ដានី ៖ អញ្ចឹង តាសេង គាត់ទៅនៅណា?

ធិន ៖ តាសេងនៅកោះកុង នៅកំពង់សោម ។

ដានី ៖ អរ, នៅកោះកុង ។

ធិន ៖ បាទ ។

ដានី ៖ អ៊ំឈប់នៅជាមួយគាត់?

ធិន ៖ បាទ ។

ដានី ៖ មកច្រើនទេគ្នា អីកងទ័ព?

ធិន ៖ កាលនោះ មកប៉ុន្តែវាបែកគ្នាចាស់ ។ ប៉ុន្តែមកនៅឯនេះទ័ពវាច្រើនដែរ ។ ទ័ពរត់មកនេះ ។ ប៉ុន្តែវាស្លាប់ច្រើន ។

ដានី ៖ ស្លាប់ច្រើន ហេរ?

ធិន ៖ អត់បាយ ។

ដានី ៖ ស្លាប់អត់បាយ ។ បាទ, ហ៊ី អញ្ចឹងអ៊ំនៅនេះ ដំបូងនៅត្រាង ហើយមកនៅកន្លែងនេះឆ្នាំណាទៅបានមកដល់ដំបូងនឹង?

ធិន ៖ នៅភូមិដូង ចេញពីភូមិដូង នៅភូមិដូងនឹងតាំងពី៧៩មក ដល់យួនមកអញ្ចឹង ដល់យើងទៅនៅភូមិដូង ។ ភូមិដូងនឹងយួនវៃចូល ទៅនៅជ្រុំ ។ជំរំសាយអេចនេះ ជំរំនេះ ។ ជំរំនឹងចេញមកពីនឹងមកនៅជំរំខ្មែរក្រហមនេះ គេធ្វើជំរំយោធា ។ នេះឆ្លងហាតនេះ ។ មកនៅឆ្លងហាតនេះ ។ ៩១ហើយនឹងចូលស្រុក មកនៅកន្លែងនេះ៩១ ។

ដានី ៖ ៩១មកនេះ?

ធិន ៖ មកនៅ ។

ដានី ៖ ៩១ ដំបូងមកនៅយ៉ាងម៉េចដែល?

ធិន ៖ សុទ្ធតែព្រៃហើយនឹង ។

ដានី ៖ សុទ្ធតែព្រៃ!

ធិន ៖ បាទ ។

ដានី ៖ ហើយឥឡូវទៅវាលអស់ហើយនឹង?

ធិន ៖ ធ្វើម៉េចបើខ្មែរមកនៅ ។ យួនដាក់ យួនដាក់នៅ នៅផ្លូវពីព្រំដែនរហូត ក្នុយមានដែលឃើញមីនសំណាក អាមីនសូវៀតមានប្រអប់ៗ ។

ដានី ៖ មិនមែនមីនស្គរទេ?

ធិន ៖ អត់ទេ, មិនសំណាកទាំងអស់ ។ យួនដាក់សុទ្ធតែមីនសំណាក ។ អាវំសែវបុប្ផាយើងមួយបន្ទុះប៉ុននេះ ៣០ខ្សែ ពីមាត់អូរមកទីនេះ ។ ៣០ខ្សែដាក់ដូចកាំអោម ។

ដានី ៖ ដាក់៣០ខ្សែ?

ធិន ៖ បាទ ។ ៣០ខ្សែហើយដាក់ពីនឹងមកដាក់អា គេថាស្នូលពោត មីនសូវៀតនឹង ។ បាទ, ចេញពីអាស្នូលពោតមក ពីរខ្សែទៀតគេថាអាពុកមាត់បង្កង ។ ពុកមាត់បង្កង់គេហៅជាន់តែជាន់មុតជើង យើងដកជើង លោតមកបង្កេះផាប់ ។ មួយខ្សែទៀត គិតទៅ៤០ខ្សែ ចេញពីនឹងមក ខ្ញុំរាវ ។

ដានី ៖ ចុះបើយើងជាន់យើងដឹងធ្វើម៉េចយើង?

ធិន ៖ តែជាន់គឺមុតជើងហើយ ។ ពីព្រោះអាវាមានម្ជុលវាមុត ។

ដានី ៖ អឺ, តែមុតជើងត្រូវតែផ្ទុះហើយ?

ធិន ៖ តែមុតជើងយើងភ្ញាក់ហើយ ។ ធម្មតាតែយើងដាក់ទៅ នឹងមុតជើង ។ ប៉ុន្តែវាមិនផាយមុត ។

ដានី ៖ ចុះបើយើងមានស្បែកជើង?

ធិន : ស្បែកជើងអត់មុតទេ ។ ប៉ុន្តែតែដកលោតតែម្តង ។ តែដកលោតហើយ រំស័រ វាលោតតែម្តង ។

ដានី : បើលោត យើងក្រាបអត់អីទេ?

ធិន : អត់ ក្រាបក៏មិនផុតដែរ ។ ៣០ម៉ែត្រ បួនជ្រុង អានឹងមីនវាប៉ុននេះ ។

វណ្ណៈ : អរ ។ អានឹងដល់ពេលហើយយើងចូលមក យើងដោះអានឹង ។

ធិន : បាទ ។ ខ្ញុំមកវាវធ្វើភូមិនេះ វាវមួយអន្តភាព មួយអន្តភាព១វាវអន្តុយមួយថ្ងៃយកតែមួយម៉ែត្រទេ ។

ដានី : មួយថ្ងៃយកតែមួយម៉ែត្រទេ?

ធិន : មួយថ្ងៃយកតែមួយម៉ែត្រ អត់មានបច្ចេកទេសទេណា ។ មានវិស្វករពីណាមកទេ ។ ដៃខ្លួនឯងកាំបិតខ្លួនឯងនឹង ។

ដានី : ប៉ុន្តែឥឡូវនឹង បាននយ័អស់ហើយ ឬក៏នូវទៀត?

ធិន : ទេ, ម្តុំនេះអស់ហើយបែប ។ ប៉ុន្តែមិនដែលឃើញផង មិនដែលប៉ះផង ។ ជាន់ក៏មិនដែល ។

ដានី : គេភ្ជួរ ហេ?

ធិន : បាទ ។

ដានី : បើមានក៏គេភ្ជួរទៅផ្ទុះអស់ដែល!

ធិន : វាខ្លាចតែមីនគោន ប៉ុនចិនមិនសាយទេនោះ ។ ប៉ុនចិនបើគេដាក់កាលនោះ គេផ្អាប់ដូចថាចាប់ទល់គ្នាអញ្ចឹងទៅណា ។

ដានី : បាទ បាទ ។

ធិន : ហើយគេដាក់អាឈើខ្ទឹមអញ្ចេះ ។ គេទល់ ហើយដាក់ក្តាទៅហើយគេចង់ក្រណាត់កៅស៊ូ ។

ដានី : បាទ, ផ្ទះអ៊ំអី ធ្វើតាំងពីឆ្នាំណាទៅ?

ធិន : ២០០៤ ។

ដានី : ២០០៤ ហេ!

ធិន : បាទ ។

ដានី : ហឹពេលដែលយើង ៩១ ចូលមកដំបូងយើងអត់ទាន់មានផ្ទះធំទេ?

ធិន : អត់ទេ, អត់ទាន់មានទេ ។ ខ្ទម ។

ដានី : ខ្ទម!

ធិន : ខ្ទមទាំងអស់គ្នា ។ ព្រៃឈើនៅពេញទឹងទាំងអស់ កាលនឹងព្រៃទល់នឹង ព្រៃហិត ។

ដានី ៖ យើងអាចកាប់ឈើយកមកធ្វើផ្ទះបានដែរ?

ធិន ៖ បាន ប៉ុន្តែកាលនឹងមានគិតអី យួននៅពេញស្រុក មានគិតធ្វើគ្នាណា។

ដានី ៖ យួននៅ?

ធិន ៖ យួននៅៗ ថានិយាយទៅថា គិតទៅថា យួន តែដូចនេះទៅយើងឆោតដូចតែគ្នា។ យួនវាមិនសូវសាប់ទេ សាប់តែខ្មែរ អាកប្រាំនោះ!

ដានី ៖ អញ្ចឹង!

ធិន ៖ បាទៗ កន្លែង ក៩ បន្តិចគេថាមក ក៩ នោះ!

ដានី ៖ ហឺៗ មក ក៩ មកម្តុំណាទៅ?

ធិន ៖ មកឯនោះ ឆ្ងាយណាពូ មិនមែនមកនេះទេ។

វណ្ណៈ ៖ ចុះខ្លះ គេថាអញ្ចេះ គេថា ពេលអ្នក ក៩ មកនឹង ខាងទាហានខ្មែរក្រហមអាណិតប្រជាជនដែលមកនឹង ឲ្យជៀសវៃតែយួនទេ។

ធិន ៖ «សើច» បេះតែថានឹង។

វណ្ណៈ ៖ នឹងហើយគេថាខាងខ្មែរក្រហម អត់មានសំលាប់ខ្មែរគ្នាឯងទេ វៃតែយួនទេ។ គេថាតាំងពីខ្ញុំ ធ្លាប់សម្ភាសន៍ទេណា!

ធិន ៖ បាទៗ

វណ្ណៈ ៖ តាំងពីខាងអន្លង់វែងមក ដូនកាលគេព័ទ្ធស៊ីតែ ដូចតា ព័ទ្ធស៊ីតែទាហានយួនទេ។ គឺអត់មានបាច់សំលាប់ខ្មែរគ្នាឯងទេ។ ក្រោយ ៩០ដាងនឹងហា?

ធិន ៖ បាទៗ

វណ្ណៈ ៖ អ៊ឹថាសាប់ខ្មែរច្រើនដាងទៅវិញ?

ធិន ៖ សាប់ខ្មែរច្រើនដាង។

វណ្ណៈ ៖ ម៉េចបានសាប់ច្រើន?

ធិន ៖ ចុះបើមក បាញ់ទៅ ដាន់មីនខ្មែរដដែល។

ដានី ៖ ដាន់មីនយើងហេ?

ធិន ៖ ដាន់មីនសាប់អាដែលនឹង។

ដានី ៖ បានន័យថាពួក ក៩ មកនឹង អត់ដឹងយើង យើងដាក់មីនដាក់អញ្ចឹងទៅ ដាក់ការពារ។

ធិន ៖ ដាក់ការពារ។

ដានី ៖ ដល់ពេលប្រជាជន ពលករហ្នឹងមក?

ធិន ៖ ចុះបើថាចាប់មិនមានអ្នកណាសំលាប់ខ្មែរទេ ។ បើថាជាន់អានឹងដូចតែគ្នាទេក្មួយ ។ យើងដាក់ការពារ ដូចថាការពារ ហើយប្អូនវាមិនមែនដើរមុនឯណា វាអត់ដើរមុនទេ ។

វណ្ណៈ ៖ បាទ!

ធិន ៖ ខ្ញុំនៅមួយជួរ៩៣នេះមិនដែលយួនដើរមុនទេ ដើរតែខ្មែរមុនទេ ។ ដល់យើងបាញ់បង្អើលទៅ អាខ្មែរនឹងវាមិនមិតទៅអញ្ចឹង ជាន់មីនអាដែល ហើយមិនរាប់ ។

វណ្ណៈ ៖ ហឺ ។

ធិន ៖ ហើយយួន ។

វណ្ណៈ ៖ តាំងពីឆ្នាំ៧០ មកអ្នកនយោបាយខ្មែរយើង ដូចចាញ់បោកបរទេសម៉េច ឃើញថាអោយខ្មែរយើងវៃខ្មែររហូត ។ ចុះបើចំពោះអ៊ំនឹង អ៊ំយល់ឃើញថាយ៉ាងម៉េចដែរអានឹង? ខ្ញុំថាលន់ នល់ ក៏ខ្មែរ សម្តេចសីហនុ ក៏ខ្មែរ ហឺ ដល់ពេលនឹងឃើញថាខ្មែរវៃគ្នា អត់មានវៃជាមួយបរទេសផង ។ អ៊ំគិតថាអ្នកនយោបាយ អ្នកដឹកនាំពីលើនឹង គេមានគំនិតយ៉ាងម៉េចដែរ? ចំពោះអ៊ំគិតម៉េចវិញ ។ ជាមតិរបស់អ៊ំ?

ធិន ៖ អត់យល់ ដល់នឹងវាមិនយល់ ដូចថាយើងថាយើងរំដោះប្រទេសពីអាណានិគមអាមេរិក ហើយគេ គេថារំដោះប្រទេសចេញពី អាណានិគមចិន ហើយយើងខុសត្រង់ថា យើងវារំលាយសាសនា អានឹងដូចថាប្រពៃណីខ្មែរ ។ នឹងដឹងហើយណា ណា? ហឺ ដល់នេះមិនដឹងថាអាណាខុស អាណាត្រូវ ក្មួយ?

ដានី ៖ បាទ ។

ធិន ៖ ខ្ញុំក៏វិភាគមិនដល់ដែរ ខ្ញុំក៏មិនចេះដែរ ។

ដានី ៖ បាទ ។ បាទ គ្រួសារអ៊ំឈ្មោះអីដែរ អ៊ំស្រី?

ធិន ៖ លី ។

ដានី ៖ ឈ្មោះ លី!

ធិន ៖ បាទ ។

ដានី ៖ អ៊ឺ, គាត់នេះ គ្រួសារអ៊ំក្រោយទេ?

ធិន ៖ បាទ ។

ដានី ៖ គ្រួសារមុន អ៊ឺ ឆ្លងទៅបានកូនប៉ុន្មាន?

ធិន ៖ អត់ទេ ។

ដានី ៖ ពេលឆ្លងទន្លេទៅ គាត់ស្លាប់ទៅ ស្លាប់ទាំងកូនទៀត?

ធិន ៖ បាុ ។

ដានី : អឺ ៗ ហើ អ៊ំមានគ្រួសារក្រោយទៀត បានកូនចៅប៉ុន្មានដែរ?

ធិន : បួននាក់ ៗ

វណ្ណៈ : បានកូនចៅបួននាក់ ៗ

ធិន : បាទ ៗ

ដានី : ហើ គ្រួសារអ៊ំមានស្រុកកំណើតនៅណាដែរ?

ធិន : នៅតាកែវ ៗ

ដានី : នៅតាកែវ!

ធិន : នៅជិតភ្នំជីសូរ ៗ

វណ្ណៈ : នៅជិតភ្នំជីសូរ ខាង អឺ?

ធិន : នៅបត់រការនឹង ៗ ផ្សារបត់រការនឹង ៗ

ដានី : អរ... ស្គាល់ហើយ ៗ នៅជិតភ្នំជីសូរនេះ ពេលយើងចូលទៅ នៅខាង សែង ទៅចេះ កោះអណ្តែតអីនឹង ៗ

ធិន : បាទ ៗ

ដានី : ផ្សារជ្រៃ ៗ ហើកូនអ៊ំធំៗអស់ហើយ?

ធិន : កូនធំ អស់ហើយ ៗ មកម៉ិញនឹង មកម៉ិញនឹង ៗ

ដានី : អរ... បាទ, ធំៗអស់ហើយ ៗ មានគ្រួសារអីអស់ហើយ?

ធិន : នៅលីវមួយ នៅលីវមួយ ៗ

ដានី : នៅលីវ ៗ ហើ, អ៊ំឥឡូវសុំសីលហើយ?

ធិន : សុំ អត់សុំទេប៉ុន្តែគ្រាន់ថាយើងនៅខាងសាសនាអញ្ចឹងទៅណា ៗ

ដានី : បាទ ៗ

ធិន : យើង មាន មាន, យើងតស៊ូរមកវាអភ័ព្វ ហើយមានប្រាក់ខែ ប្រាក់អី ៗ មកគេឲ្យទៅវៃខ្មែរគ្នាឯង ឈប់ធ្វើតែម្តង ៗ

ដានី : អឺ, ឈប់ហេរ?

ធិន : ឈប់ ៗ

ដានី : បាទ ៗ

ធិន : ដល់ដាចខ្លួនហើយ អាពេលគេទៅវៃកោះកុងវិញ ខ្ញុំនៅយោធាដែរ នៅទ័ពដែរ ប៉ុន្តែកាលនឹងអន្តរភាពគេថាឲ្យទៅវៃ តានេះ នៅកោះកុងនឹង ៗ

ដានី : តា ណា?

ធិន ៖ ដាន ។

ដានី ៖ អៀង ដាន?

ធិន ៖ អឺ ។

ដានី ៖ ចុះ អ៊ំស្គាល់ តាផាត ឬអត់? តាផាត ។

ធិន ៖ តាផាត ណា?

ដានី ៖ តាផាត គាត់មេកង មេទ័ពដែរ ។

ធិន ៖ អត់ដឹងទេ ។

ដានី ៖ នៅខាងកោះកុង ។ នៅសំឡូត-កោះកុង ។

ធិន ៖ អត់ទេ ។ អត់ស្គាល់ទេ ។

ដានី ៖ តាផាត, តាផល អឺ ។

ធិន ៖ អរ, អត់ស្គាល់ទេ ។

ដានី ៖ អត់ស្គាល់ទេ!

ធិន ៖ ស្គាល់តែតា ។

ដានី ៖ តាផាត?

ធិន ៖ តាផាត អត់ស្គាល់ទេ ។

ដានី ៖ បាទ, ខ្ញុំអរគុណអ៊ំច្រើនដែលផ្តល់បទពិសោធន៍អ៊ំ ដល់ពួកខ្ញុំនេះបានយល់ដឹងទាក់ទងនឹងរឿងកោះមួយចំនួន ។ បាទ, អ៊ំ អរគុណអ៊ំច្រើន ។

ចប់